# គតិលោក

រីច្បាប់ទូន្មានខ្លួន

រៀបរៀងដោយ អុកញ៉ាសុត្តន្តប្រីជាអិន្ទ

ភាគទី១

| | | |
|---|---|---|
| ១ - ប្រវត្តិ អុកញ៉ាសុត្តន្តប្រីជាអិន្ទ | ២ - ប្រស្នាអំពីគតិលោក | ៣ - ធម៌ដែលគ្រហស្ថត្រូវប្រព្រឹត្ត |
| ៤ - ប្រស្នារឿងស្រីល្អ ទឹកផ្អែម | ៥ - ទោសកើតអំពីជក់អាភៀន កញ្ឆា | ៦ -ប្រស្នារឿងពាលគួរអោយខ្លាច |
| ៧ -រឿងយុនវ៉ាតចាញ់បោកចៅពាល | ៨ -រឿងចៅពាលក្លែងភេទជាសង្ឃ | ៩ -រឿងពាលសង្រួមហួសប្រមាណ |
| ១០ -រឿងតាថេននិសិស្សពនាក់ | | |

# បវត្តិពង្សាវតារអុញ៉ាសុត្តន្តប្រីជាអិន្ទ

អុកញ៉ាសុត្តន្តប្រីជា អិន្ទកំណើតកើតនៅស្រុកទន្លេធំ គឺភូមរកាកោងខេត្តមុខកំពូល មាតាឈ្មោះយាយមុំ បិតាឈ្មោះបញ្ចាងកែ អុកញ៉ាកើតថ្ងៃចន្ទ ខែអាសាធ ឆ្នាំរក ពុទ្ធសករាជកន្លងទៅបាន ២៤០៣វស្សាគឺថ្ងៃទី២២ សូយេត ឆ្នាំ១៨៥៩, កាលអាយុ ១០ឆ្នាំនៅវត្តសិក្សាអក្សរខ្មែរ អាយុ១៥ឆ្នាំចេញរៀនប្រែព្រះបរិយត្តិ បួសជាសាមនេរ រួចទៅរៀននឹងលោកព្រះអាចារ្យពេជ ស្រុកព្រះត្រពាំង, អាយុ១៨ឆ្នាំទៅរៀននឹងលោកគ្រូព្រះពុទ្ធឃោសាចារ្យប្រាក់ វត្តអុណ្ណាលោមក្រុងភ្នំពេញ,អាយុ១៩ ឆ្នាំ ទៅរៀននឹងលោកគ្រូព្រះអាចារ្យសុខ វត្តកែវ ស្រុកបាត់ដំបង, អាយុ២០ ឆ្នាំបានបួសជាភិក្ខុនៅវត្តកែវ ១វស្សាទើបលាព្រះអុបជ្ឈាយាចារ្យទៅរៀន នៅស្រុកបាងកកក្រុងស្យាម រៀនបាន៧វស្សាក៏វិលមកស្រុកខ្មែរវិញ ក្នុងអំណាចលោកព្រះយ៉ាកថាថន(ញ៉ុញ) នៅវត្តកណ្តាល ស្រុកបាត់ដំបង រួមបាន១០វស្សា លាសិក្ខាបទសឹកមកមានបុត្រភរិយានៅភូមិថ្វាធំ លោក កថាថន(ឈុំ) ចិញ្ចឹមជាទី ហ្លួងវិចិត្រវោហារបាន តែងបានប្រែបាលីជាសំរាយមានឈ្មោះ៤៤ ឈ្មោះជាសៀវភៅខ្លះ ចារស្លឹករិតខ្លះ, លុះអាយុបាន៥៥ឆ្នាំ រាជការក្រុងភ្នំពេញ អោយយកមកតាំងទីជា អុកញ៉ាសុត្តន្តប្រីជា ប្រោសអោយជួយតែងសព្វវចនាធិប្បាយខ្មែរ នៅទីសាលាបាលី ក្នុងរវាងអាយុ ៥៥ឆ្នាំ ដល់អាយុ៦៥ឆ្នាំ បានលារាជការវិលមកនៅស្រុកបាត់ដំបងដើមវិញ លុះនៅថ្ងៃ ១០កើត ខែអស្សុជ ឆ្នាំជូត ឆស័ក មានរោគក្អក បណ្តាកូនចៅរាល់គ្នា នាំគ្នាប្រតិបត្តិប្រកបថ្នាំ រកគ្រូរក្សាពុំចេះធូរឡើយ លុះដល់ថ្ងៃ អាទិត្យ ១២កើត ខែកត្តិកឆ្នាំជូត ឆស័ក ក៏ទទួលអនិច្ចកម្មនៅវេលាម៉ោង៨ព្រឹក គឺថ្ងៃ ៨ណូវ៉ែម ឆ្នាំ ១៩២៤។

# ប្រស្នាអំពីគតិលោក

តំរាគតិលោកនេះ គឺខ្ញុំបាទទីអុកញ៉ាសុត្តន្តប្រីជាអិន្ទ អ្នកតែងឡើង ដើម្បីកុលបុត្រ អ្នករៀនគតិបុរាណជាបែបយ៉ាង គ្រាន់អាងសេចក្ដីប្រៀបនាំយកប្រារព្ធ គតិលោកថ្មី ដែលកើតមានឡើង ទើបតាំងជាពាក្យបុច្ឆានិងពាក្យវិសជ្ជនាក្នុងតំរានេះជាទី សណ្ដាប់ដោយងាយ។ ដើមឡើយ កូនសិស្សសួរគ្រូថាសូមទានមេត្តាប្រោសពាក្យដែលថា គតិលោកនោះ តើប្រែដូចម្ដេច?។ គ្រូប្រាប់ថាគតិលោកនោះប្រែថា ដំណើរប្រព្រឹត្តទៅរបស់ជនក្នុងលោកិយនេះអែង។

ស. លោក សព្ទនេះ តើអធិប្បាយជាពាក្យសំរាយថាដូចម្ដេច?

គ. អោ! លោក ជាសភាវៈដែលកើតឡើងដោយអំណាចបដិសន្ធិនៃខន្ធ គឺថាសភាវៈមិនទៀងដោយមិនជាប់នៅមិនប្រាកដជាអទស្សនភាព, មួយទៀតប្រែថា សត្វផែនដីផ្ទៃមេឃ អាកាសទូទៅទាំងអស់,លោកនេះប្រែថា ធម្មតាសត្វ រឺ របស់ដែលប្រព្រឹត្តទៅក្នុងលោក, អែគតិសព្ទនោះប្រែបានច្រើនយ៉ាងគឺថាដំណើរទៅគ្រឿងដល់គ្រឿងដំណើរបទសេចក្ដី កំលាំង អំណាច ផ្លូវទីពឹង ក្ដីអត់ធន់ ចិត្តកំណើតពាក្យអែណាហេតុអែណា ដែលកើតឡើងមានឡើងក្នុងលោកនេះ ហៅថាគតិលោកទាំងអស់។

ស. សួរថា លោកនេះមានតែ១ រឺ មានច្រើនយ៉ាងតទៅទៀត?

គ. ឆ្លើយថា លោកនេះ បើយោគយកគតិធម៌មកសំដែងចេញទៅទៀតនោះមានច្រើនយ៉ាងតទៅគឺអារម្មណ៍ទាំងពួងមានរូបដែលឃើញនឹងភ្នែកជាដើមនោះហៅថា កាមលោក រូបដែលឃើញដោយចិត្តជាដើមនោះហៅថា រូបលោក ដោយហោចទៅ យ៉ាងសព្វសារពើទាំងពួង បណ្ដាដែលមានចិត្តគ្រប់គ្រងព្រមនៅក្នុងសភាវប្បញ្ញត្តិ។

ស. សួរថាលោកយើងនេះ ហៅថា មនុស្សលោកអែខាងស្ថានទេវតានោះហៅថា ទេវលោក ហើយចុះដូចជាមនុស្សលោកយើងនេះ បែងចេញជាស្ថានមាន ប៉ុន្មានជាន់ ស្ថានទេវលោកនោះតើមានប៉ុន្មានជាន់?

គ. ឆ្លើយថា សត្វក្នុងមនុស្សលោកយើងនេះបែងចេញជាពីរជាន់ គឺសត្វតិរច្ឆានជាន់១ មនុស្សជាន់១ រួមនៅក្នុងលោក

ជាមួយគ្នា។ សត្វក្នុងបរលោកបែងជា៤ស្ថាន គឺនរកប្រេត អសុរកាយស្ថាន១ ទេវតាក្នុងឆកាមាវចរសួគ៌ស្ថាន១ រូបព្រហ្មស្ថាន១ អរូបព្រហ្មស្ថាន១ នៅក្នុងលោកខាងមុខទាំងអស់ សត្វក្នុងមនុស្សលោក ជាពួកមានកាយគ្រោតគ្រាត សត្វក្នុងទេវលោកជាពួក មានកាយទិព្វខ្លះ ដែលពុំមានកាយជាពួកសោយអារម្មណ៍ គឺជាទិព្វខ្លះ ដែលប្រាសចាករូបខ្លះ។

ស. សួរថា សត្វលោកទាំងពួង ដែលនឹងកើតឡើងនោះ តើអាស្រ័យធម្មជាតិអ្វី អោយកើត ដែលកើតនោះដូចគ្នារឺខុសគ្នា?

គ. ឆ្លើយថា សត្វលោកទាំងពួងដែលនឹងកើតនោះ អាស្រ័យដោយបុញ្ញាភិសង្ខារខ្លះ តែចំណែកខាងមនុស្សលោកនេះ ប្រកបដោយអារម្មណ៍ ដែលជាអុតុនិយមនិងពីជនិយម និងកម្ម ៣ប្រការផងគ្នា។

- អុតុនិយមនោះ បានខាងអែរបស់ធាតុ គឺជាជាតិដីថ្មីក្រួសរវានផ្សេងៗ
- ពីជនិយមនោះ បានខាងរុក្ខជាតិ តិណជាតិស្មៅវល្លិផ្សេងៗ។
- កម្មនិយមនោះ បានខាងអែបសាទរូប ដែលជ្រួតជ្រាបទៅក្នុងកាយសត្វជាដើម ព្រមទាំងវេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងទ្វារទាំង៦ រួមអារម្មណ៍៣ប្រការនេះ ផ្សំចូលគ្នាជារាងកាយទើបបានជាសត្វទាំងពួងក្នុងមនុស្សលោក។

អែចំណែកខាងទេវលោកនោះ មានតែអារម្មណ៍ដែលជាផលនៃកម្មម្យ៉ាង គឺអុបបាតិកៈកំណើត ១ទៀតអែផែនដីដែលជាទីអាស្រ័យនៅរបស់សត្វនិងរាងកាយរបស់សត្វ និងសារពើទាំងពួងក៏កើតអំពីកម្មនិយមទាំងអស់។ មនុស្សលោកជាហេតុ ទេវលោកជាផល សំរាប់ក្ដីរស់នៅរបស់លោកទិព្វ។ ទេវលោកជាហេតុ មនុស្សលោកជាផល សំរាប់ក្ដីរស់នៅរបស់លោកមនុស្ស។

ស. សួរថា សត្វលោក ដែលកើតមកជាមនុស្សយើង ហេតុអ្វីក៏ខុសគ្នា។

គ. ឆ្លើយថា ការដែលប្លែកគ្នានោះព្រោះសង្ខារតាក់តែងដោយអំណាចបុណ្យ និងបាប ដែលសត្វកសាងមកអំពីបុព្វជា

តិ សត្វទាំងឡាយបណ្តាដែលមានចិត្តគ្រប់គ្រង នៅជាដើមនេះ ក៏ជាធម៌និងលោកផ្សំគ្នាដូចយ៉ាងធាតុទង់ហ្វា ដែលជារបស់កើតអំពីធាតុមាស និងទង់ដែងផ្សំគ្នាដូច្នោះសត្វទាំងឡាយផ្សេងគ្នា ក៏ព្រោះធម៌ និងលោកដែលផ្សំគ្នានោះ មានចំណែកតិចច្រើនផ្សេងគ្នាព្រោះធាតុទង់ដែងដែលផ្សំគ្នា និងធាតុមាសនោះតិចច្រើនជាងគ្នាយ៉ាងនោះ អែងចូលចិត្តរឺទេ? បើពុំចូលចិត្តយើង នឹងញែកចិត្តចេញ ជាលោក ជាធម៌ អោយយល់ក្នុងកាលឥលូវនេះ។

ស. ករុណា ពុំទាន់ចូលចិត្តសព្វគ្រប់ទេ និមន្តលោកគ្រូម្ចាស់ញែកអោយទានស្តាប់បាន?

គ. អើអែងចាំស្តាប់ហ្ន៎ា ពណ៌លឿងៗដែលឆ្លុះទៅក្នុងសាច់ទង់ហ្វានោះ ជាជាតិមាស ពណ៌ក្រហមមួយៗក្នុងសាច់ទង់ហ្វានោះ ជាជាតិទង់ដែង មានអុបមាយ៉ាងណាចិត្តរបស់សត្វដែលមានសេចក្តីចេះដឹងនោះជាជាតិធម៌អែកាយរឺ អារម្មណ៍របស់សត្វដែលប្រាសចាកក្តីចេះដឹងនោះជាជាតិលោក សេចក្តីនោះមានអុបមេយ្យដូច្នេះអែង ចិត្តនេះជាជាតិធម៌ទើបពុំស្លាប់តែកាយរឺ អារម្មណ៍ជាតិលោក ទើបត្រូវស្លាប់ ជាធម្មតាមាសបរិសុទ្ធក្នុងសាច់ទង់ហ្វានោះពុំមែនទង់ហ្វាគឺជាមាសចំណែក១ផ្សេង ដូចគ្នាយ៉ាងនោះអែង ហេតុនោះទើបសត្វលោកកើតឡើងខុសគ្នា ដោយអំណាចផ្សំធាតុ គឺបុញ្ញាភិសង្ខារដែលជាបុណ្យនិងអបុញ្ញាភិសង្ខារដែលជាបាប។

ស. ករុណាលោកគ្រូអធិប្បាយមកនេះ ក៏ចូលជាគតិធម៌ច្រើនៗ ខ្ញុំព្រះករុណាស្តាប់បានហើយ តែខ្ញុំករុណាត្រូវការចង់ដឹង ចង់ចេះតែក្នុងគតិលោកចំណែក១ សូមទានអត់ទោស មនុស្សយើងសព្វថ្ងៃនេះ ពុំដូចគ្នានោះព្រោះសាងមកខុសគ្នា ហើយតាមគតិធម៌ តែខាងគតិលោក លោកយោគជាដូចម្តេចវិញដូចមនុស្សខ្លៅល្ងង់នោះតើកើតឡើងដោយហេតុអ្វីមនុស្សអិតមិត្តសំលាញ់នោះ តើកើតឡើងដោយហេតុអ្វី មនុស្សអិតក្តីសុខនោះ តើកើតឡើងដោយហេតុអ្វី សូមលោកគ្រូម្ចាស់អធិប្បាយអោយទានតាមគតិលោកពិតៗ?។

គ. ឆ្លើយថា អោ!រឿងនោះ បើនឹងនិយាយដោយគតិលោកក៏ឃើញថាមនុស្សល្ងង់ខ្លៅនោះ មិនពីព្រោះហេតុអ្វី ព្រោះតែសេចក្តីខ្ជិលប៉ុណ្ណោះអែង ដូចបទក្នុងគម្ពីរលោកនិតិថាៈ

អលសស្ស កុតោសិប្បំ អសិប្បស្ស កុតោធនំ អធនស្ស

កុតោមិត្តំ អមិត្តស្ស កុតោ បុញ្ញំ អបុញ្ញស្ស កុតោ សគ្គំ។

ប្រែថា សិល្បសាស្រ្តចំណេះវិជ្ជាមានមកអំពីទីណា ដូចម្តេចបានដល់អ្នកខ្ជិលសេចក្តីខ្ជិលនោះមាននៅហើយវិជ្ជាទាំងពួងក៏ពុំអាចមានដល់មនុស្សឡើយបើចំណេះ វិជ្ជាមិនមានហើយ ទ្រព្យសម្បត្តិនឹងកើតមានមកអំពីទីណាដូចម្តេចបានកាលបើ ទ្រព្យសម្បត្តិមិនមានហើយ ធ្វើម្តេចឡើយនឹងមានមិត្រសំលាញ់គេរាប់អាន គឺថាពុំមានបុគ្គលអែណា១ នឹងចូលមកជាមិត្តជាភ័ក្តិជាពួកឡើយកាលបើមិនមានមិត្តភ្វាហើយសេចក្តីសុខសប្បាយអែណាក៏មាន នឹងមានតែសេចក្តីទុក្ខលំបាកជាប្រក្រតី កាលបើមានតែក្តីលំបាកទុក្ខហើយចិត្តគិតកសាងមគ្គផលកុសលសីលទាននឹងគេអែណាមានកាលបើពុំមានកុសលបុណ្យទានហើយធ្វើម្តេចឡើយ នឹងបានសម្បត្តិសួគ៌និព្វាននឹងគេ ហេតុដច្នេះបានជាថា សេចក្តីខ្ជិលនេះ ជានីវរណធម៌ហាមមិនអោយបានប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ អែងចូលចិត្តចុះ។

ស. ករុណា ខ្ញុំព្រះករុណាចូលចិត្តហើយប៉ុន្តែដែលព្រះករុណាម្ចាស់ថា ចំណេះវិជ្ជានោះ គឺសិល្បវិជ្ជាអ្វីដែលជាវិសេសលើសវិជ្ជាទាំងពួងក្នុងលោកនេះ?

គ.អើរឿងសព្វវិជ្ជានោះ គឺវិជ្ជាអក្សរនោះអែង ជាវិជ្ជាវិសេសលើសវិជ្ជាទាំងអស់ ក្នុងលោក តែងប្រជុំចុះក្នុងវិជ្ជាអក្សរចំណែក១ទាំងអស់ ព្រោះវិជ្ជាអក្សរនេះ ជាវិជ្ជា ដំបូងជាងវិជ្ជាទាំងពួង ប្រៀបដូចកែវសំរាប់ឆ្លុះមើលវត្ថុទាំងពួង បើវិជ្ជាអក្សរនេះកើតវិបត្តិវិបល្លាសទៅកាលណាហើយ វិជ្ជាទាំងពួងក៏ពុំអាចតាំងនៅបាន ព្រោះពុំមានទីចំណាំទៅបានហេតុនោះទើបថា វិជ្ជាអក្សរនេះវិសេសលើសជាងវិជ្ជាទាំងពួង។ មួយទៀត អ្នកពុំចេះអក្សរនោះ ប្រៀបដូចជាបុគ្គលមានចក្ខុងងឹត នឹងមើលនូវរូបារម្មណ៍ទាំងពួងមិនឃើញ អ្នកដែលចេះអក្សរនោះ ប្រៀបដូចបុគ្គលមានចក្ខុបរិបូណ៌ នឹងចង់មើលអ្វី ក៏អាចមើលបានទូទៅ។

ស. ករុណា ដែលលោកគ្រូម្ចាស់អធិប្បាយថា អ្នកពុំចេះអក្សរប្រៀបដូចមនុស្សខ្វាក់ អ្នកដែលចេះអក្សរថា ដូចជាបុគ្គលបរិបូណ៌ដោយចក្ខុប្បសាទ បទពីរយ៉ាងនេះ ខ្ញុំព្រះករុណាស្តាប់បាន តែពុំសូវយល់សេចក្តីសព្វគ្រប់ សូមនិមន្តលោកគ្រូម្ចាស់អធិប្បាយអោយពិស្តារទៀត?។

គ. អោអែងនៅសង្ស័យអ្វីទៀត បើដូច្នេះយើងនឹងសួរអែងវិញថា មានហឹបរឺ កញ្ជើ១ ដែលគេដាក់គ្រឿងមាសគ្រឿងប្រាក់ គ្រឿងស្ពាន់លាយចូលគ្នា ហើយមនុស្ស ខ្វាក់នោះអាចយល់ស្គាល់របស់ទាំងអស់នោះបានរឺទេ? អាចដឹងថា វត្ថុនេះជាមាស វត្ថុនោះជាប្រាក់ ជាស្ពាន់រឺទេ?។

ស. ករុណាធម្មជាតិមនុស្សខ្វាក់នោះ ពុំអាចនឹងមើលយល់ស្គាល់បានឡើយ មនុស្សដែលមានចក្ខុប្បសាទបរិបូណ៌ទើបអាចមើលយល់ស្គាល់បាន។

គ. អើដូចគ្នា មនុស្សខ្វាក់មើលវត្ថុពុំយល់ ស្គាល់ជាមាសជាប្រាក់នោះ លោកប្រៀបដូចមនុស្សពុំចេះអក្សរអ្នកពុំចេះអក្សរទុកស្មើនឹងមនុស្សខ្វាក់ អ្នកចេះអក្សរ ទុកស្មើនឹងមនុស្សបរិបូណ៌ដោយចក្ខុប្បសាទ។មួយទៀតវិជ្ជាអក្សរនេះទុកស្មើភ្នែកទិព្វមាត់ទិព្វក៏បាន ដូចយ៉ាងសព្វតំរាទាំងពួង មានតំរាភូមិសាស្ត្រ តំរាពង្សាវតារជាដើម ជារបស់បុរាណកន្លងទៅយូរហើយ យើងចេះអក្សរបានអានមើល ក៏អាចដឹងរឿងរ៉ាវបាន និយាយប្រាប់គ្នាគ្នីបាន យ៉ាងនេះទុកស្មើយើងមានភ្នែកទិព្វ។ មួយទៀតយើងនៅស្រុកនេះនឹងនិយាយ រឺប្រាប់កិច្ចការ រឺ ចង់ដឹងការអ្វីៗ អំពីបែបអ្នកស្រុកអែនោះក្តីប្រើតែអក្សរទៅ គេក៏បានដឹងច្បាស់ វិជ្ជាអក្សរនេះអាចចារឹកពាក្យសំដីបានសព្វប្រការ តំកល់ទុកនៅអស់កាលជាអង្វែង។ មួយទៀត បើបានចេះខាងអក្សរលោកអ្នកប្រទេសក្រៅមានអក្សរសៀម រឺអក្សរបារាំងសេសជាដើមផង ក៏រឹតតែកើតចំណេះជាតិយ្យោភាពអាចដឹងវិធីក្នុងប្រទេសនោះៗ បានទូទៅដូចអ្នកមានកូនសោ អាចចាក់សោបើកហិប មើលរបស់ក្នុងហិបនោះបានដោយងាយៗ កើតបញ្ញាក្លាហាន ព្រោះបានដឹងក្បួនខ្នាតបែបផែនក្រៅស្រុកមិនសង្ស័យ ហេតុនោះទើបយើងពោលថា សព្វវិជ្ជាទាំងពួងក្នុងលោកនេះ សឹងមានទីរៀនចប់ទៅបាន តែវិជ្ជាអក្សរ១ នេះជាវិជ្ជារៀនពុំចេះចប់ ព្រោះជាវិជ្ជាវិសេស លើសវិជ្ជាទាំងពួងក្នុងលោកនេះ គួរអែងចូលចិត្តចុះ។

ស. ករុណា ខ្ញុំករុណាស្តាប់បានចូលចិត្តហើយ ចុះវិជ្ជាអ្វីទៀតដែលជាវិជ្ជាបន្ទាប់ រងវិជ្ជាអក្សរនេះទៅ?

គ. វិជ្ជាលេខ ជាវិជ្ជាបន្ទាប់រងពីវិជ្ជាអក្សរនេះ លេខនិងអក្សរជាវិជ្ជារួមនៅជាមួយគ្នា។

ស. សូមទាន ចុះវិជ្ជាទាំងអស់ក្នុងលោកនេះបុគ្គលអែណារៀនចេះចាំបានហើយ សឹងនាំមកនូវប្រយោជន៍ដល់បុគ្គល

នោះៗ បានទទួលសេចក្តីចំរើនដូចម្តេច រឺមានវិជ្ជាអែណា១ ជាសឹកសត្រូវដល់បុគ្គលអ្នកចេះនោះខ្លះដែរ?

គ. ថាវិជ្ជាក្នុងលោកចាត់ជាពីរប្រការ គឺទុវិជ្ជាប្រការ១ សុវិជ្ជាប្រការ១ វិជ្ជាណាដែលបុគ្គលចេះដឹងហើយសំដែងឡើង ធ្វើឡើងអាចនឹងនាំមកនូវសេចក្តីទុក្ខ សេចក្តីវិនាសផលប្រយោជន៍ដល់បុគ្គលដទៃផង ដល់អាត្មាអែងផង យ៉ាងនោះហៅថា ទុវិជ្ជា ពិតមែនវិជ្ជាអែណាដែលបុគ្គលសំដែងឡើង ធ្វើឡើងហើយអាចនឹងនាំមកនូវសេចក្តីសុខ សេចក្តីចំរើនដល់បុគ្គលដទៃផង ដល់អាត្មាផង យ៉ាងនេះវិជ្ជានោះឈ្មោះ សុវិជ្ជាបុគ្គលអែណាទ្រទ្រង់នូវចំណែកសុវិជ្ជា បុគ្គលនោះទទួលសេចក្តីសុខសេចក្តីចំរើន សួស្តីមង្គល បុគ្គលអែណាទ្រទ្រង់នូវចំណែកទុវិជ្ជា បុគ្គលនោះទទួលសេចក្តីទុក្ខទោសសេចក្តីវិនាស សុវិជ្ជា ជាគុណដល់អ្នកចេះដឹង ទុវិជ្ជា ជាទោសដល់អ្នកដែលទ្រទ្រង់នោះ។

ស. សូមទានអត់ទោសចុះ បុគ្គលខ្លះមានវិជ្ជាចំណេះខ្ពស់ហើយ តែធ្លាក់ខ្លួនចុះចាកវិជ្ជានោះវិញ ទទួលតែសេចក្តីទុក្ខទោស គរហានិន្ទា វិជ្ជាដែលចេះដឹងហើយប្រើវិញពុំបានយ៉ាងនេះ គឺហេតុអកុសលអ្វី?

គ. ថាអ្នកនោះមានវិជ្ជាខ្ពង់ខ្ពស់ល្អហើយ តែធ្វើអោយវិជ្ជាប្រើពុំបានវិញនោះ ព្រោះអិតមារយាទ អិតក្តីហិរិអោត្តប្បៈគ្មានខ្មាសបាប ខ្លាចបាប ប្រព្រឹត្តខ្លួនទៅ តាមគតិមនុស្សពាលផ្សេងៗ យ៉ាងបុគ្គលនោះអែងទើបត្រូវទទួលក្តីទុក្ខទោសគរហានិន្ទាគ្រប់ប្រការក្នុងលោកនេះ។

ស. ចុះមនុស្សយើងធ្វើខ្លួនអោយបរិសុទ្ធនោះតើត្រូវប្រព្រឹត្តយ៉ាងណា?

គ. ថា អែការដែលនឹងធ្វើនូវខ្លួនអោយបរិសុទ្ធនោះ គោងចំរើននូវសេចក្តីសុខដល់អ្នកដទៃ ទើបខ្លួនបានទទួលសេចក្តីបរិសុទ្ធនោះ បើអោយទុក្ខគេហើយក្តី ទុក្ខនោះអែងនឹងមានដល់ខ្លួនវិញមិនខាន ខ្លួនអែងនឹងទទួលក្តីបរិសុទ្ធអែណាបាន។

ស. មនុស្សយើងដែលលោកសន្មតហៅថាមនុស្សល្អនោះ តើមានអាការកិរិយាយ៉ាងណា ដែលហៅថាមនុស្សអាក្រក់នោះ តើមានអាការកិរិយាយ៉ាងណា?

គ. ថាមនុស្សដែលល្អនោះ គឺមនុស្សណាប្រកបដោយក្តីសុចរិត៣ប្រការ គឺកាយសុចរិត១ វចីសុចរិត១ មនោសុចរិត១

ប្រព្រឹត្តខ្លួនជាបុគ្គលប្រដៅងាយ មានហិរិអោត្តប្បៈជាជញ្ជាំង រឹកំផែងបិទបាំងកាយមិនអោយអកុសលធម៌ចូលញាំញី ខ្លួនបានយ៉ាងនេះ មនុស្សនោះរែងហៅថា មនុស្សល្អបាន។ មនុស្សប្រកបដោយក្តីទុច្ចរិត ៣ប្រការគឺ កាយទុច្ចរិត១ វចីទុច្ចរិត១ មនោទុច្ចរិត១ ប្រព្រឹត្តខ្លួនជាបុគ្គលប្រដៅក្រ ពុំមានហិរិអោត្តប្បៈធម៌បិទបាំងកាយ ហើយផ្សាយចិត្តក្នុង ការអកុសលផ្សេងៗ វង្វេងដោយគតិពាលពិត មនុស្សយ៉ាងនេះរែងហៅថា មនុស្សអាក្រក់ក្នុងលោក យើងនេះ

# ធម៌ដែលគ្រហស្ថត្រូវប្រព្រឹត្ត

ស. សូមទានមេត្តាប្រោស ពាក្យសុភាសិតប្រដៅថា អោយវៀរក្តីកេស៊ីក្នុងការមិច្ឆាជីវៈ អោយរកស៊ីតាមផ្លូវសម្មាជីវៈ ផ្លូវមិច្ឆាជីវៈនោះដូចម្តេច ផ្លូវសម្មាជីវៈនោះដូចម្តេច?

គ. អោ! ផ្លូវមិច្ឆាជីវៈនោះ គឺក្រេបការរកស៊ីខុសកន្លងធម៌ មានលក់ដូរគ្រឿងសស្ត្រាប្រហារជីវិតសត្វជាដើមមានលក់ដូរថ្នាំបំពុលជាបរិយោសាន ព្រមទាំងប្រព្រឹត្តធ្វើ ជាបន្ទាល់កោងទាំងឆក់កុហកគេដោយអុបាយដោយគំនិតកោងផ្សេងៗ ការរកស៊ីខុសនឹងទទួលទុក្ខទោមនស្សផ្សេងៗ អែការរកស៊ីផ្លូវសម្មាជីវៈនោះគឺវៀរបង់ផ្លូវមិច្ឆាជីវៈនេះអែង ហៅថាចិញ្ចឹមជីវិតដោយធម៌ ឈ្មោះថាសម្មាជីវៈ ១ទៀតត្រូវ វៀរផ្លូវដែលមហាក្សត្រទ្រង់ហាម ដូចយ៉ាងគយដារដែលរាជការតាំង ហើយទៅប្រព្រឹត្តកន្លងព្រះរាជអាជ្ញា យ៉ាងនេះប្រការ១ ត្រូវវៀរផ្លូវល្បែងផ្សេងៗ មានល្បែងជល់មាន់ ជល់ត្រីជាដើមនេះប្រការ១ ត្រូវវៀរល្បែងស្រី ល្បែងស្រា វៀរសេពគប់គឿន ពាលនាំលេងយប់ ស្វែងមើលល្បែងផ្សេងៗ មានល្បែងច្រៀងរាំជាដើមយ៉ាងនេះប្រការ១។

ស. សូមទាន ការត្រាច់យប់នោះមានទោសយ៉ាងណាខ្លះ?។

គ. អោ ការដែលដើរលេងយប់នោះ មានទោស៥ប្រការគឺៈ

- ដើរទៅហើយខាតផ្លូវរាំងរក្សាផ្ទះ ទីលំនៅខ្លួន ជូនប្រពន្ធកូន រឺបងប្អូនកើត ហេតុដោយរោគាព្យា រឺដោយហេតុអែណា១ក្តី ចំណែកខ្លួនមិនដឹងក៏ខូចប្រយោជន៍ទៅជាទោស១។
- ជួនកាលដើរទៅហើយ ពើបប្រទះលើសត្វមានពិសវាចឹក វាខាំបាននូវទុក្ខវេទនាយ៉ាងនេះជាទោស១
- ជួនកាលដើរទៅជាន់ជើងចោរ ដែលគេដេញចោរមក អាចោរវាវេះបាត់ទៅ គេឃើញអែង គេក៏ចាប់ថាជាចោរយ៉ាងនេះជាទោស១។
- ជួនដើរទៅហើយប្រទះនឹងចោរ រឺអ្នកដែលមានពៀរវេរាជល់អ្នកអែណា១ គេឃើញអែងក៏សំគាល់ជាចោរ រឺថាអ្នកដែលមានពៀរនោះ គេបាញ់ចាក់សំលាប់ ទៅយ៉ាងនេះជាទោស១។

- អ្នកដើរយប់ ជាទីនាំអោយគេគរហានិន្ទាថាបាន គឺថាបើគេបាត់របស់ទ្រព្យអ្វីអែណា១ គេជិតចិត្តសង្ស័យឆ្នៃថាអែង ព្រោះឃើញថាអែងដើរលេងយប់យ៉ាងនេះជាទោស១។

ស. សូមទាន ការដែលកើតមកជាមនុស្សនេះត្រូវបែងកាលប៉ុន្មានកាល?

គ. ត្រូវបែងកាលតាមវ័យទាំង ៣ប្រការ គឺហៅថា បឋមវ័យប្រការ១ ហៅថា មជ្ឈិមវ័យប្រការ១ ហៅថាបច្ឆិមវ័យប្រការ១ ក្នុងបឋមវ័យនោះត្រូវស្វែងរករៀន វិជ្ជាសិល្បសាស្ត្រ និងចំណេះទាំងពួង លុះដល់មជ្ឈិមវ័យ គឺវេលាដែលតាំងនៅក្នុងកាលខ្លួនមានបុត្រភរិយា ហើយត្រូវប្រកបការផ្លូវរកស៊ីមានផ្លូវជួញ ផ្លូវធ្វើស្រែចំការជាដើម សន្សំទ្រព្យសម្បត្តិអោយកើតមាន លុះដល់បច្ឆិមវ័យជាវ័យខាងចុង គឺខ្លួនចាស់ជរាហើយត្រូវស្វែងរកផ្លូវកុសល គឺបរិច្ចាគទានរក្សាសីលចំរើនភាវនា ជាបច្ច័យរបស់ខ្លួនទៅបរលោក។

ស. មាតាបិតាមានគុណូបការដល់បុត្រ បុត្រគួរសង្គ្រោះដោយផ្លូវប៉ុន្មានប្រការ?

គ. បុត្រត្រូវសង្គ្រោះមាតាបិតាដែលជាបុព្វការីនោះដោយបទសង្គ្រោះ៥ប្រការគឺ

- ករណំ គិតថាអាត្មាអញនេះ គឺមានមាតាបិតាលោកចិញ្ចឹមមកយូរហើយគួរតែចិញ្ចឹមលោកវិញ។
- កិច្ចករណំ ការងារនៃមាតាបិតាមានឡើង ត្រូវបញ្ឈប់ការងាររបស់ខ្លួនសិន ទៅជួយធ្វើកិច្ចការមាតាបិតានោះត្រាតែបានសំរេច។
- កុលវង្សថបនំ កូនត្រូវប្រព្រឹត្តរក្សាវង្ស តម្កល់វង្សនៃត្រកូលអោយឋិតថេរនៅ ការកេរ្តិ៍មាតាបិតាកុំអោយសាបសូន្យវិនាសទៅបាន។
- ទាយជ្ជារហាបដិបជ្ជនំ កូនត្រូវបំរើមាតាបិតាដោយសុចរិត តាំងចិត្តលំអោន គោរពកោតខ្លាច អាចទទួលនូវទ្រព្យមត៌ករបស់មាតាបិតា។
- ទក្ខិណានុប្បទានំ  បើមាតាដល់នូវមរណភាពហើយ កូនត្រូវទទួលតបគុណ ដោយធ្វើឈាបនកិច្ច ធ្វើបុណ្យ

សាងកុសលបញ្ជូនផលទក្ខិណានុប្បទានទៅមាតាបិតា ដែលលោកចែកស្ថានទៅបរលោកនោះ។

ស ប្តីសង្គ្រោះប្រពន្ធមានប៉ុន្មានប្រការ ប្រពន្ធសង្គ្រោះប្តី តើមានប៉ុន្មានប្រការ?

គ ប្តីសង្គ្រោះប្រពន្ធនោះមាន៥ ប្រការគឺ

- សមាននាយ ប្រដៅសព្វសារពើ ពោលពាក្យពិរោះ សរសើរដោយលក្ខណៈ ប្រព្រឹត្តជាប្រយោជន៍ពោលពាក្យជាបិយវចនៈ។
- អវិមាននាយ ពុំមើលងាយជេរវាយដូចទាសីទាសាកម្មករឡើយ។
- អនតិចរិយាយ ពុំប្រព្រឹត្តបែកចិត្តពីភរិយា មិនកន្លងចិត្តភរិយា គឺមិនមានស្រ្តីដទៃទៀតជាភរិយាឡើយ។
- អិស្សរិយវោស្សគ្គេន ប្រគល់នូវរបស់ទាំងពួង មានផ្ទះបាយជាដើមអោយដល់ភរិយា។
- លង្ការានុប្បទានេន អោយនូវគ្រឿងប្រដាប់មានសំពត់អាវជាដើម អោយភរិយាដោយសមគួរតាមបវេណី។

ប្រពន្ធសង្រោះប្តីមាន៥ប្រការគឺៈ

- សុសំវិហិតកម្មន្តា ចាត់ចែងការងារដោយប្រពៃ និងតាក់តែងភោជនាហារ មិនអោយហួសពេលវេលា។
- សង្គហិតបរជនា ប្រពន្ធត្រូវសង្គ្រោះដល់ជនក្នុងផ្ទះ និងញាតិខាងប្តី រាប់អានអោយដូចជាញាតិរបស់ខ្លួន។
- អនតិចារិនី មិនប្រព្រឹត្តកន្លងចិត្តប្តី គឺមិនមានបុរសដទៃជាប្តីឡើយ។
- សមតញ្ញ អនុរក្ខតិ រក្សាទ្រព្យសម្បត្តិដែលប្តីរកបានមកមិនអោយអន្តរាយដោយការមិនគួរ។
- ទក្ខា ច ហោតិ អនលសា ឈ្លាសក្នុងការស្រ្តីរឹមិនខ្ជិលច្រអូស។

មាតាបិតាអនុគ្រោះបុត្រដោយបទ៥ប្រការគឺៈ

- បាបា និវារេន្តិ ហាមកូនចាកផ្លូវបាបគឺកុំអោយធ្វើបាបកម្ម។

- កល្យាណេ និវេសេន្តិ ញ៉ាំងកូនអោយតម្កល់នៅក្នុងការកុសល។
- សិប្បំ សិក្ខាបេន្តិ ញ៉ាំងកូនអោយសិក្សារៀនសូត្រសិល្បសាស្រ្តផ្សេងៗ។
- បដិរូបេន ទារេន សំយោជេន្តិ លុះកូនធំឡើង ត្រូវប្រកបការរកភរិយា ដែលមានរូបមានសម្បត្តិ សមគួរផ្សំអោយកូន គឺរៀបអាពាហ៍ពិពាហ៍អោយកូន។
- ទាយជ្ជំ និយ្យាទេន្តិ ប្រគល់ទ្រព្យមតិកអោយក្នុងសម័យដ៏សមគួរ គឺអោយក្នុងនិច្ចសម័យ១ ក្នុងកាលសម័យ១។

ស. បុគ្គលដែលគួរយើង នឹងបូជាគោរពក្នុងលោកនេះ មានប៉ុន្មានយ៉ាង?

គ. បុគ្គលដែលគួរនឹងបូជានោះ ចែកដោយអុក្រិដ្ឋមាន៣យ៉ាងគឺ ព្រះសម្មាសម្ពុទ្ធ១ ព្រះបច្ចេកពុទ្ធ១ ព្រះអរិយសាវក១ ចែកដោយសាមញ្ញទៀត គឺចំណែកខាងបព្វជិតនោះ យកអុបជ្ឈាយាចារ្យជាទីគោរពបូជារបស់កូនសិស្ស១ ភិក្ខុមានវស្សាចាស់ជាទីគោរពបូជារបស់ភិក្ខុខ្ចី១ ប៉ែកខាងឃរាវាសនោះ គឺបងប្រុសបងស្រីជាទីគោរពបូជា របស់ប្អូនៗ១ មាតាបិតាជាទីគោរពបូជា របស់កូនប្រុសកូនស្រី១ ស្វាមីអាពុកក្មេកម្តាយក្មេកជាទីគោរពបូជារបស់ភរិយាកូនប្រសា១។

ស. កើតមកជាមនុស្សក្នុងលោកនេះ ត្រូវធ្វើពលិកម្មប៉ុន្មានយ៉ាង?។

គ. អោ! ពលិកម្មនោះមាន ៥យ៉ាង អ្នកអែងស្តាប់ចុះៈ

- ញាតិពលិ អធិប្បាយថា បុគ្គលជាញាតិសាលោហិតរបស់ខ្លួនពិតៗ ខ្លួនគួររាប់អានជួយទំនុកបំរុងដោយអោយនូវវត្ថុផ្សេងៗ មានបាយទឹកប្រាក់មាសជាដើម
- អតិថិពលិ អធិប្បាយថា បុគ្គលជាភ្ញៀវទើបដល់មកកាន់ទីលំនៅខ្លួន ខ្លួនគួរ ធ្វើបដិសណ្ឋារសួរទទួលរាប់អានតាមសម័យ គឺអោយនូវបច្ច័យមានភោជនាហារជាដើម។
- បុព្វេបេតពលិ អធិប្បាយថា ញាតិមិត្រអែណារស់នៅក្តី មរណភាពទៅកាន់ បរលោកហើយក្តីគួរធ្វើការកុសលអែណា១ អុទ្ទិសផលជូនទៅដល់ញាតិនោះ។
- រាជពលិ អធិប្បាយថា រាជការរបស់មហាក្សត្រមានឡើង គួរខ្លួនទទួលរាជការឆ្លងព្រះតេជព្រះគុណរីទទួលបង់

ថ្លៃរាជការ។

- ទេវតាពលិ អធិប្បាយថា ពួកទេវតាទាំងឡាយ បណ្ដាដែលមានសក្កានុភាព បានជួយសង្គ្រោះដោះទុក្ខខ្លួន គួរធ្វើសក្ការបូជាដល់ទេវតាទាំងឡាយនោះ។

អំពេលិការនោះ គួរយើងបូជាដល់បុគ្គល៥ជំពូក ដូចសេចក្ដីដែលបានអធិប្បាយមកនេះ។

# ប្រស្នារឿងស្រីល្អទឹកផ្អែម

ស. ស្ត្រីយ៉ាងណា ហៅថាល្អលើសស្ត្រីទាំងពួងក្នុងលោកនេះ ទឹកយ៉ាងណា ជាទឹកផ្អែមឆ្ងាញ់លើសទឹកទាំងពួងក្នុងលោកនេះ ត្រីយ៉ាងណា ដែលមានរសជាតិឆ្ងាញ់ ពិសាលើសត្រីទាំងពួងក្នុងលោកនេះ?។

គ. អោ អែជាតិស្ត្រីល្អលើសគេនោះ បើតាមនិយាយដោយរូប គឺស្រីដែលប្រកបដោយបញ្ញាពិធធម៌គឺស្ត្រីដែលមានសីលមារយាទល្អនោះអែង បើនិយាយដោយវោហារិញនោះ គឺស្ត្រីប្រពន្ធគេនោះអែង ហៅថាល្អលើសលែងស្ត្រីក្នុងលោក ហេតុអ្វីក៏បានជាថាលើសគេនោះ ព្រោះស្ត្រីប្រពន្ធគេនោះមានទោសខុសទាំងពីរផ្លូវ ថាបើបុរសណាទៅប្រព្រឹត្តកន្លងបវេណីនោះហើយ គឺក្នុងលោកនេះ តែគេដឹងលឺហើយ គេក៏ចាប់ទៅប្តឹងដល់សាលាជំនុំ សាលាជំនុំលោកក៏ពិនិច្ឆ័យលក់ រឺដាក់គុក ធ្វើទោសទៅផ្សេងៗ អែខាងផ្លូវបរលោកនោះសោត ក៏បានបាបគឺ ធ្លាក់ទៅសោយទុក្ខវេទនាក្នុងអបាយភូមិទាំង៤ មាននរកជាដើម ការដែលដឹងថាមានទោសយ៉ាងនេះហើយ ហេតុអ្វីបុរសលែងពុំបានបើដូច្នេះស្ត្រីនោះមិនល្អលើសគេហើយហះ បានជាបុរសលែងពុំបាន យ៉ាងនេះអែងហៅថា ស្ត្រីល្អលើសលែងក្នុងលោក។

២ - អែទឹកដែលផ្អែមពិសាលើសទឹកទាំងពួងនោះ គឺសុរានេះអែង មែនពិតអែទឹកសុរាបានជាផ្អែមលើសលែងនោះព្រោះទឹកសុរានោះ មានអំណាចអាចហាម មិនអោយបិទ មិនអោយធ្វើខ្លួនអែង គោងចេញប្រាក់ទៅទិញចិន អែទោសផឹកសុរា គឺបង់ប្រាក់១ គឺផឹកទៅហើយ កើតស្រវឹងវង្វេងចិត្ត ទៅប្រព្រឹត្តការជូរអាក្រក់ផ្សេងៗ មានបង្កពាក្យជម្លោះប្រកែកប្រកួតជាដើម១ មានទោសធ្លាក់ទៅអបាយភូមិទាំង៤ មាន នរកជាដើម១ អ្នកលេងសុរា សឹងដឹងប្រាកដថា ផឹកសុរានោះជាទីនាំមកនៅសេចក្តីទុក្ខទោសទាំងអស់ តែនឹងលះលែងពុំបាន បើដូច្នោះសុរានោះមិនជាផ្អែមលើសគេហើយហះ បានជាមនុស្សយើងលះលែងពុំរួច។

៣ -អែត្រីដែលមានរសពិសាលើសត្រីនានានោះគឺត្រីព្រលូងនោះអែង បានជាថាត្រីព្រលូងមានរសពិសានោះព្រោះដឹងថាត្រីព្រលូងនេះ ជូនបរិភោគទៅហើយពុលក៏មាន តែនឹងលះបង់ពុំបាន បើដូច្នោះត្រីព្រលូងនោះមិនឆ្ងាញ់លើសគេ

ហើយហះ បានជាមនុស្សលះលែងពុំបាន។

ស. ករុណាចូលចិត្តហើយ ១ទៀតការទទួលទានសុរានោះ ហេតុអ្វីថាមានបាប សុរានោះទទួលទានទៅជាថ្នាំកែរោគ ក៏មាន ជាគុណអោយទទួលទានបាយបានក៏មានសូមនិមន្តលោកគ្រូកែ ខៃអោយចូលចិត្តបន្តិចមើល?។

គ. តបថា ការផឹកសុរានោះ បានជាបាបព្រោះព្រះបរមគ្រូទ្រង់ហាមពុំអោយសេពសុរានោះ ព្រោះជារបស់នាំអោយស្រវឹង នាំអោយខូចចិត្ត ត្បិតមនុស្សយើងសព្វថ្ងៃនេះ មានស្រវឹងនៅពេញខ្លួនហើយ សេចក្តីស្រវឹងនេះ លោភោគឺសេចក្តី ជាប់ជំពាក់ រឺចំណង់ចង់បាននេះជាស្រវឹងប្រការ១ ទោសោគឺសេចក្តីក្រោធខឹងនេះស្រវឹងប្រការ១ មោហោ គឺសេចក្តីល្ងង់វង្វេងពុំស្គាល់ខុសត្រូវនេះស្រវឹងប្រការ១ មានៈទិដ្ឋិគឺ សេចក្តីរឹងត្អឹងកាន់ខ្លួន អួតខ្លួននេះជាស្រវឹងប្រការ ១ ស្រវឹងទាំងអស់នេះ តែងមាននៅសំរាប់រូបមកហើយ ហើយមកថែមផឹកទឹកស្រវឹងចូលទៅទៀតស្រវឹងថ្មី ក៏នាំស្រវឹងចាស់អោយមានកំលាំងក្លាហានឡើង គឺខ្លួនអ្នកលោភក៏នាំអោយលោភខ្លាំងឡើង ខ្លួនអ្នកទោសៈ រឺមោហៈមានៈទិដ្ឋិ ក៏នាំអោយចំរើន ទោសៈមោហៈ មានៈទិដ្ឋិខ្លាំងក្លាឡើង មួយទៀតពាក្យជាអាថិកំបាំង រឺកេរ្ត៍ខ្មាសជារបស់មិនគួរនឹងចេញសំដែងប្រាប់គេនោះក៏អាចនាំចេញបង្ហាញគេបានទាំងអស់ មួយទៀតនាំអោយកើតជំលោះប្រកែក ជួនក៏ត្រូវព្រះរាជអាជ្ញាបង់ទ្រព្យធនទៅផ្សេង ផ្សេងមួយទៀត ទោសសុរានេះនាំអោយកើតរោគឆាប់ងងឹតភ្នែក ឆាប់ជរាគ្រាំគ្រាទ្រោមទ្រុឌ ទោសយ៉ាងនេះអែង បានថាមានក្នុងលោកនេះ មួយទៀតប្រាក់ដែលទៅទិញសុរា នោះក្នុងមួយឆ្នាំៗបើប្រមូលទុក គង់បាននៅច្រើន គ្រាន់ទុករក្សាការពារអន្តរាយក្នុងគ្រាក្រ ទុកទិញបាយត្រីចំណីអែទៀតចៃកកូនប្រពន្ធអាស្រ័យជាជាង រឺអែងយល់ដូចម្តេច។

## ទោសកើតអំពីជក់អាភៀននិងកញ្ឆា

ស. ករុណា ខ្ញុំករុណាចូលចិត្តហើយ អើយ៉ាងជក់អាភៀនជក់កញ្ឆានោះ តើមានទោសយ៉ាងណាខ្លះទាន?។

គ. អោ រឿងជក់អាភៀនជក់កញ្ឆានោះ មានទោសប្រហែលៗ នឹងសុរានោះដែរ អែងគិតមើលចុះ សុរាអាភៀននោះសឹងមានផាស៊ីគេទិញដាច់មុខក្នុងស្រុកមួយៗ ធ្វើលក់បានតែម្នាក់ៗ ម្ល៉ោះហើយ គេចង់តំឡើងថ្លៃយ៉ាងណា ក៏តាមតែ

ចិត្តគេទាំងអស់ តំលៃនោះលើសប្រមាណ ឃើញចុះទុនយ៉ាងច្រើនៗ បើខ្លួនទៅប្រកបគិតធ្វើឡើងបានតែនាយផាស៊ី គេដឹងហើយគេក៏ចាប់លក់ព្វៃតាមច្បាប់ព្រះរាជបញ្ញាត្តិ ត្រូវបង់ប្រាក់ ធ្លាក់ដល់ទោសជាប់គុកជាប់ក្តីក្នុងលោកនេះ។ ១ទៀត អ្នកជក់អាភៀននោះ សព្វថ្ងៃនេះអែងយល់ស្រាប់ហើយ អ្នកណាមានរូបល្អខ្លះ អ្នកល្អណាគេគាប់ចិត្ត សេចក្តីចំរើនមានយ៉ាងណាខ្លះ គួរអែងគិតមើលចុះ អែរឿងកញ្ឆាទៀត ក៏ប្រហែលៗនឹងអាភៀនដែរ សឹងជារបស់នាំអោយកាយវិកលវិការ នាំអោយឆ្កួតចិត្តប្រព្រឹត្ត ទៅក្នុងកិរិយាទាបថយទាំងអស់។

## ប្រស្នារឿងពាលដែលគួរអោយខ្លាច

ស. ករុណា ខ្ញុំយល់ហើយទាន មួយទៀតការគួរអោយខ្លាចក្នុងលោកនេះតើអោយខ្លាចអ្នកណាទាន?។

គ. អោ ការដែលខ្លាចនោះ ក្នុងចិត្តគំនិតអែងតើខ្លាចអ្វីសព្វថ្ងៃនេះ?។

ស. ខ្ញុំព្រះករុណាសព្វថ្ងៃនេះគិតខ្លាចស្តេច១ ខ្លាចអ្នកមានទ្រព្យសម្បត្តិ១ យ៉ាង នេះត្រូវរឺមិនត្រូវ?

គ. អែងគិតខ្លាចស្តេច ខ្លាចអ្នកមានទ្រព្យសម្បត្តិនោះមិនត្រូវទេ ខ្លាចអីស្តេចនោះ បើយើងទៅប្រព្រឹត្តការអែណាអោយខុសនឹងព្រះរាជបញ្ញាត្តិ ក្រិត្យព្រះអាជ្ញា គឺយើងទៅធ្វើការខុស មានធ្វើចោរកម្មជាដើមនោះទើបមហាក្សត្រលោកដាក់ទោសទណ្ឌកម្មយើងបាន បើយើងរក្សាខ្លួនយើង អោយត្រឹមត្រូវតាមច្បាប់ហើយ យើងប្រព្រឹត្តកាយប្រព្រឹត្តចិត្តសុចរិត តាមព្រះរាជប្រកាសហើយ ស្តេចនោះលោក នឹងដាក់ទោសទណ្ឌកម្មយើងអែណាបាន អែអ្នកមានទ្រព្យសម្បត្តិនោះសោត បើយើងកុំទៅខ្ចីទ្រព្យគេយើងកុំទៅពឹងទ្រព្យគេ គេនឹងមកធ្វើទោសយើងអែណាបានហេតុនោះទើបថា យើងមិនត្រូវខ្លាច។

ស. ចុះលោកគ្រូអោយខ្លាចមនុស្សយ៉ាងណាវិញ?

គ. ត្រូវអោយខ្លាចមនុស្សពាលជំពូក១ ទើបត្រូវព្រោះមនុស្សពាលក្រនឹងគេចរត់អំពីវាទៅបាន ពាលនោះពុំប្រាកដថានៅត្រង់នេះត្រង់នោះបាន ជួនណាកូនប្រពន្ធអែង បងប្អូនអែង ត្រឡប់ជាពាលវិញក៏មាន ពាលនេះរក្សាក្រពេកណា

ស់កុំថាដល់ពាលខាងក្រៅនោះឡើយ តែពាលខាងក្នុងនៅជាមួយនឹងខ្លួនក៏ពុំដឹងថាជាពាលមកដល់ថ្ងៃណា ខែណាពេលណា ដូចប្រពន្ធដែលរួមសុខទុក្ខផងគ្នា ជួនណាក៏ប្រែចិត្តគិតស្អប់ប្ដី ទៅស្រលាញ់ប្រុសដទៃប្រើសហាយវាអោយបុរហារប្ដី ដល់នូវសេចក្ដីស្លាប់ទៅវិញក៏មាន អែរឿងនិទានប្រពន្ធសំលាប់ប្ដី រឿងបុរាណមាននិយាយមកថា

## រឿងប្រពន្ធចិត្តពាល

មានបុរសម្នាក់មានភរិយាជាទីគាប់ចិត្ត នៅរួមសុខទុក្ខនឹងគ្នាអស់កាលជាយូរមក តែបុរសនោះមានប្អូនប្រុសម្នាក់យកមកនៅរកស៊ីជាមួយផង លុះនៅយូរមកមេប្រពន្ធនោះ ទៅប្រតិព័ទ្ធស្រឡាញ់ថៅប្អូន ថ្ងៃមួយបានលួចលាក់ធ្វើស្មគ្រសង្វាសនឹងគ្នា ដល់ក្រោយមេនោះនិយាយញុះថៅប្អូនថ្លៃអោយសំលាប់ប្ដី អែថៅប្អូនថ្លៃនោះ ហេតុតែជាមនុស្សលុះក្នុងអំណាចភ្លើងរាគខ្លាំង ក៏លុះពាក្យញុះញង់នោះ កើតទ្រុស្តមិត្ត ទ្រុស្តបងអាត្មាទើបកាន់ដាវទៅចាំនៅនាកំពង់ទឹកលុះបងទៅងូតទឹកថៅប្អូននោះ ក៏ពិឃាតបងនោះដល់នូវមរណភាពកាលកណ្ដាលផ្លូវទៅ ហើយក៏បានយកគ្នាជាប្ដីប្រពន្ធមក។ រឿងរ៉ាវនេះ មានសេចក្ដីពិស្ដារក្នុងព្រះគម្ពីរសង្គហអែនោះ អញ្ជើញទៅមើលចុះ។

មានរឿងក្នុងកាលអិលូវនេះក៏មានដូចរឿងស្ត្រីម្នាក់នៅស្រុកចកខេត្តត្នោត ស្ត្រីនោះជាកូននាយជាងមាស មាតាបិតាដាក់ទុកអោយមានស្វាមី លុះនៅយូរមក មេនោះមានសហាយក្បត់កើតស្អប់ប្ដីអាត្មា ទើបវានិយាយបញ្ឆោតប្ដីនោះអោយទៅបោចវល្លិក្នុងព្រៃស្ងាត់ ហើយវាអោយសហាយនោះ ទៅតាមសំលាប់ថៅប្ដីនោះចោល។

១ទៀតមានមេម្នាក់ប្រពន្ធមេឃុំ នៅភូមិស្រុកស្ទោងជីក្រែង ស្ត្រីនោះអែងទៅ សហាយ នឹងថៅអធិកាម្នាក់ កើតស្អប់ប្ដីអាត្មា ទើបវាទៅជួលអ្នកលេង អោយបាញ់មេឃុំជាប្ដីស្លាប់ទៅ។ រឿងអស់ទាំងនេះមានសេចក្ដីពិស្ដារ នៅក្នុងពាក្យបណ្ដឹងក្នុង សាលាវិនិច្ឆ័យអែនោះ។

## រឿងកូនពាល

គឺកូនជាអវជាតបុត្រ អកតញ្ញូពុំដឹងគុណមាតាបិតា អាចសំលាប់មាតាបិតា ដូចនិទានព្រះមោគ្គល្លានត្ថេរកាលនៅក្នុងអតីតជាតិនៅឡើយ លោកកើតជាមាណពម្នាក់ លុះអំណាចមេភរិយា វាញុះអោយមាណពនោះនាំមាតាបិតាទៅសំលាប់ចោលបង់ក្នុងព្រៃ មាណពនោះត្រូវទោសអនន្តរិយកម្ម ធ្លាក់ទៅសោយទុក្ខវេទនា ក្នុងមហាអវចីនរកអស់កំណត់ លុះដល់ភទ្ទកប្បនេះ គ្រាដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់យើងបានត្រាស់ឡើង មាណពនេះបានមកកើតជាព្រះមោគ្គល្លានត្ថេរ ជាអគ្គសាវកខាងឆ្វេង។ រឿងបិតុឃាត ដូចនិទានព្រះបាទអជាតសត្រូវទៅសេពគប់នឹងទេវទត្ត កើតមោហចិត្តគិតចង់បានរាជសម្បត្តិព្រះវររាជបិតា ចាប់ព្រះបាទពិម្ពិសាររាជ ជាព្រះវររាជបិតាប្រហារជីវិតដល់នូវមរណភាពទៅ។ រឿងនិទានអស់នេះ មានសេចក្តីពិស្តារក្នុងព្រះគម្ពីរមង្គលត្ថទីបនី អែនោះហេតុនោះទើបហៅថា មនុស្សពាលនោះគួរខ្លាចក្រៃពេកណាស់ ព្រោះនៅជិតជាប់ នឹងអាត្មាពុំដឹងជានឹងកើតមកក្នុងថ្ងៃណា នឹងគេចរត់អោយផុតចេញពីវាទៅបាន។

១ទៀត អែនុស្សពាលនេះ ចេះអុបាយកល បញ្ឆោតបញ្ចុកច្រើនយ៉ាងណាស់ តែពុំមានបញ្ញាត្រិះរិះគិតអោយដឹងកលអាការវាហើយ ក៏នឹងបង់ខ្លួនបង់ទ្រព្យទៅដោយអំពើពាលនោះពុំខាន ដូចនិទានយុនវ៉ាតអោយមនុស្សពាលវាធ្វើបានអែនិទាននោះដោយលឹថា

# រឿងឃុនរ៉ាតចាញ់បោកចៅពាល

មានកាលថ្ងៃ១ មានមនុស្សម្នាក់ វាយកខ្សែមាសមួយ ខ្សែឡើងទៅលើផ្ទះឃុនរ៉ាត ហើយវានិយាយថា «ខ្ញុំបាទទ័លចាយពេកណោស់ ខ្ញុំយកខ្សែនេះមកបញ្ចាំ នឹងលោក សូមបញ្ចាំទុកប្រាក់ ៣០រៀល ខ្ញុំបាទជូនការលោក១ខែ ៣កាក់ៗរៀងទៅ សូមលោកមេត្តាជួយដោះធុរៈខ្ញុំបាទម្តងនេះទៅ»។ ឃុនរ៉ាតថា: «ខ្សែអែងនេះមាសទំងន់ប៉ុន្មានជំឡឹងប្រាប់មក? ថា:«ខ្សែខ្ញុំបាទនេះធ្វើមកទំងន់៣តំឡឹង២ជី»

ឃុនរ៉ាតថា «ខ្សែអែងនេះក្រែងក្រលៃទេដឹង យើងនៅសង្ស័យណាស់? «បាទខ្សែខ្ញុំបាទនេះ គឺមាសសុទ្ធពិតប្រាកដមែន បើលោកមិនជឿខ្ញុំបាទ សូមអញ្ជើញលោក  យកទៅអោយជាងគេសាក  រឺកាត់មើលចុះ  បើទៅជាក្រលៃដូចពាក្យលោកថានោះ ខ្ញុំបាទហ៊ានអោយលោកេធ្វីទោសខ្ញុំបាទដោយប្រការផ្សេងៗ»។ ឃុនរ៉ាតក៏យកខ្សែនោះ ទៅអោយជាងទងគេមើល។ នាយជាងទងនោះបានកាត់មើលបន្តិចទៅ ក៏ឃើញជាមាសប្រាកដ  ទើបជំរាបឃុនរ៉ាតថា មាសមែនហើយលោក ចូរលោកទទួលយកទុកចុះមិនខាតទេ ទើបឃុនរ៉ាតវិលមកផ្ទះ  ហើយនិយាយកត់ត្រាសញ្ញាឈ្មោះ នឹងចៅនោះព្រមចិត្តគ្នា ទើបយកប្រាក់៣០រៀលប្រគល់អោយទៅចៅនោះ ចៅពាលបានប្រាក់ហើយ ក៏លាឃុនរ៉ាតមកទីលំនៅអាត្មា។ លុះអស់ខែ១ ចៅពាលក៏យកប្រាក់ការមកជូនឃុនរ៉ាតនោះ តែដល់ទេសកាលមានវិធីបុណ្យ រឺការមង្គល ប្រជុំមហាជនកាលណាក៏យកខ្សែនោះពាក់ប្រដាប់អាត្មាទៅកាលនោះ  លុះកន្លងខែ៣មក  ចៅពាលក៏យកប្រាក់ ៣០រៀលដើមនិងប្រាក់ការទៅលោះខ្សែពីឃុនរ៉ាត  ឃុនរ៉ាក៏ទទួលប្រាក់  ហើយប្រគល់ខ្សែនោះទៅចៅពាលវិញ។ ចៅពាលក៏លាឃុន រ៉ាតមកកាន់ទីលំនៅខ្លួន  លុះនៅយូរបន្តិចមក  ចៅពាលយកខ្សែនោះទៅបញ្ចាំអោយឃុនរ៉ាតម្តងទៀត បញ្ចាំជាន់ក្រោយនោះឡើងថ្លៃ៥០រៀល  ឃុនរ៉ាតក៏ទទួល  បញ្ចាំដូចជាន់មុនលុះនៅយូរបន្តិចមកចៅពាលយកប្រាក់ ៥០ (ប្រហែលជាមានការសរសេរខុស ប្រាក់ដើម៥០រៀល មិនមែន៥០រៀលទេ?) រៀលនិងការប្រាក់ទៅលោះយកខ្សែអំពីឃុនរ៉ាត។ លុះកន្លង៥ខែមកចៅពាលធ្វើខ្សែក្រឡៃ១ មានរូបសណ្ឋានភាពនូវក្បាច់ ទាំងទំនងដែលជាងកាត់បន្តិចនោះក៏ដូចគ្នានឹងខ្សែជាន់មុនហើយចៅពាល យកទៅបញ្ចាំអោយឃុនរ៉ាតទៀត បញ្ចាំឡើងថ្លៃ៦០រៀល

។ អែយុនវ៉ាតក៏ពុំបានត្រួតត្រាមើលអោយម៉ត់ចត់ព្រោះខ្សែនោះដូចគ្នានឹងជាន់មុន ដែលចៅពាលយកទៅបញ្ចាំ យុនវ៉ាតទុកចិត្តអិតសង្ស័យ ទើបទទួលបញ្ចាំខ្សែក្រលៃ នោះនឹងចៅពាល បានប្រគល់ប្រាក់៦០រៀលអោយចៅពាល ចៅពាលទទួលយក ប្រាក់ហើយក៏លាយុនវ៉ាតវិលទៅកាន់ទីលំនៅខ្លួនដូចដើម លុះនៅយូរបន្តិច ចៅពាលក៏យកប្រាក់៦០រៀលនិងការទៅលោះខ្សែក្រលៃអំពីយុនវ៉ាត យុនវ៉ាតក៏ទទួលយកប្រាក់ ហើយទៅយកខ្សែនោះហុចអោយចៅពាល ចៅពាលទទួលយកមក ក៏ធ្វើជាពិនិត្យមើលចុងដើមខ្សែនោះហើយក្លែងនិយាយបញ្ជាក់ថា «ខ្សែនេះមិនមែនជាខ្សែខ្ញុំបាទទេលោក ម្តេចក៏លោកយកខ្សែក្រឡៃតែផ្កាសពីណាមកអោយខ្ញុំបាទដូច្នោះវិញ ខ្សែខ្ញុំបាទនេះមាសពិតៗលោក» អែយុនវ៉ាតក៏ឆ្លើយថា «ខ្សែនោះអែងហើយជារបស់អែង យើងនឹងមានខ្សែអែណាមកលាយឡំច្រឡំគ្នានោះក៏ទេ មានតែខ្សែចៅអែងមួយប៉ុណ្ណោះអែង ហេតុម្តេចក៏ថាពុំមែនវិញដូច្នោះ យើងទៅឆីឆចៅអែងអែណាបាន» ចៅពាលក៏ថាមែនយ៉ាងរូបខ្ញុំបាទជាអ្នកទ័លក្រមកកោងឆីឆបោកកុហកអ្វីពីលោកអោយខូចផ្លូវមេត្រីនោះ តែខ្សែខ្ញុំបាទមាសពិតៗដូចលោក បានអោយជាងសាកមើលពីដើមហើយ ក៏អែខ្សែនេះជាខ្សែកាលៃសោះខ្ញុំនឹងទទួលយកម្តេចបាន លោកយកខ្សែតែផ្កាសមកអោយខ្ញុំបាទយ៉ាងនេះ បើលោករកខ្សែ មាសនោះពុំបាន សូមអោយលោកសងថ្លៃខ្សែខ្ញុំបាទជាប្រាក់១៣៥រៀល។ យុតវ៉ាត លឺចៅពាលថាដូច្នោះក៏កើតទោសោខ្លាំងហើយថា «អែងមិនសុខចិត្តយកខ្សែនេះ ក៏តាមចិត្តចុះ រឺចង់ទៅប្តឹងសាលាណាក៏តាម ខ្មោចអាខ្មោច ខ្សែផង់អែងហើយនៅថាមិនមែនទៀត ទៅអោយឆាប់ទៅកុំមកតឈ្លោះអ្វីនឹងអញ»។

អែចៅពាលពុំទទួលយកខ្សែ ហើយក៏ចុះអំពីផ្ទះយុនវ៉ាតទៅពឹងចៅស្មាក្តីម្នាក់អោយធ្វើរឿងរ៉ាវប្តឹងចោទយកតួយុនវ៉ាតកោងឆខ្សែ តាមសេចក្តីគ្រប់ប្រការ ហើយចៅពាលក៏យកពាក្យនោះ ចូលប្តឹងដល់សាលាចៅក្រម ចៅក្រមសាលាកាលទទួលពាក្យបណ្តឹងនោះ ហើយទើបមានដិកាហៅរូបយុនវ៉ាតមកសួរចំលើយ។

អែយុនវ៉ាតក៏ធ្វើពាក្យអោយការឡើងតាមដំណើរអំពីដើមដល់ចុងជូនដល់ចៅក្រម  ចៅក្រមសាលាយកពាក្យចោទពាក្យចំលើយមកជំរះទៅ  ក៏យល់សេចក្តីខាងពាក្យចោទពោលអាងនាយជាង ទងជាសាក្សីទើបហៅយកសាក្សីនោះ

មកអោយស្បថ ជាបន្ទាល់អោយការ អែនាយជាងទងនោះក៏ឆ្លើយអោយការថាខ្លួនបានកាត់ខ្សែមើលជាមាសមែន អែត្រង់ចៅពាលផ្លាស់ប្តូរលោះទៅហើយយកមកបញ្ជាំ ២-៣ដងទៀតនោះជាងទងសាក្សី ពុំដឹង ទើបឆ្លើយថាខ្សែនោះ ជាមាសពិតមែនដូចពាក្យចោទ ទើបចៅក្រមកាត់ក្តីនោះអោយយុនវ៉ាតចាញ់ចៅពាល យុនវ៉ាតត្រូវសងថ្លៃខ្សែមាសជាប្រាក់១៣៥រៀលផង ត្រូវបង់ប្រដាប់ក្តីជូសចៅពាលផង សងសោហ៊ុយទាំងអស់ផង។

រឿងយុនវ៉ាតចាញ់ក្តីចៅពាលនេះ អែងស្តាប់មើលចុះជាតិមនុស្សពាលវាចេះអុបាយកល ធ្វើអោយយុនវ៉ាតដល់នូវសេចក្តីវិនាស ហេតុនោះទើបថាមនុស្សពាល មានលក្ខណៈសណ្ឋានយ៉ាងនេះយ៉ាងនោះទៅបាន។

អែមនុស្សស្រុកយើងសព្វថ្ងៃនេះ ដឹងតែថាអ្នកណាផឹកស្រាជក់អាភៀន ស្លៀកពាក់សើយលាត់ រឺដើរក្រលៃក្រលបង្ក ពាក្យជំលោះប្រកែកទៅផ្សេងៗ នោះទើបដឹងថា អ្នកនោះជាមនុស្សពាលមែន អែត្រង់ពាលវាក្លែងធ្វើកិរិយាប្រើអាការស្លៀកពាក់រៀបរយសំដែងកិរិយាសុភាពរាបសានោះ មិនស្គាល់ឡើយបណ្តាអ្នកនគរ ដែលរាប់អានព្រះពុទ្ធសាសនានេះ តែឃើញមនុស្សកោរក្បាល ស្លៀកស្បង់ពាក់ចីពរហើយក៏តាំងសំគាល់ថា ជាមនុស្សត្រឹមត្រូវបរិសុទ្ធទុកចិត្តជឿរាប់អាន ដល់មនុស្សពាលវាយល់ភេទនោះហើយទើបវាក្លែងលួចភេទនោះ មកធ្វើជាភិក្ខុ រឺសាមេណរ ដើរកុហកបញ្ឆោតអ្នកនគរអោយខូចផលប្រយោជន៍ទៅផ្សេងៗក៏មានដូចនិទានពីមនុស្សម្នាក់គេហៅថា ចៅពាលត្បាល់ក្លៀង មានរឿងមកថា៖

# រឿងចៅពាលក្លែងភេទជាសង្ឃធ្វើគ្រូមើលស្កន់

កាលនោះ មានមនុស្សស្រីម្នាក់ តាំងលំនៅ នៅភូមិស្វនចំការ ផ្ទះនោះនៅដាច់ពីគេ នាងនោះមានកូនខ្ចីអាយុប្រហែល ៨-៩ខែ តាំងពីប្ដីស្លាប់ទៅ នាងនោះក៏មេម៉ាយនៅតែជាមួយនឹងបងប្អូន អែកូនខ្ចីនោះពុំសូវជា ជួនកើតរោគគ្រុនស្កន់ ជាន់ម្ដងៗ កើតរីងរៃស្គមលឿង លុះនៅយូរបន្តិចមក មានមនុស្សម្នាក់ដឹងថានាងមេម៉ាយនោះមានសម្បត្តិច្រើនទើប វាស្វែងរកមើលចន្លោះអោកាស នឹងទៅបញ្ឆោតកុហកបោកប្រាសនាងមេម៉ាយនោះ។

លុះដល់វេរកាលគេច្រូតស្រូវ ទើបបងប្អូនញាតិមិត្រដែលនៅជាមួយផងនោះគេនាំគ្នាទៅច្រូតស្រូវទាំងអស់គ្នា នៅតែនាងមេម៉ាយនៅចាំផ្ទះ មនុស្សពាលនោះ កាលណាបានអោកាសហើយ វាក៏កោរក្បាលហើយលួចយកស្បង់ចីពរលោកសង្ឃ ដែលគេគរចោលតាមគល់ពោធិមក ស្លៀកពាក់ធ្វើអាការកិរិយា ជាលោកសង្ឃ ដើរត្រង់ទៅផ្ទះនាងមេម៉ាយនោះ លុះដល់ហើយវាធ្វើជាដើរឈរវេរានៅមុខផ្ទះ អែនាងមេម៉ាយនោះអង្គុយនៅរានហាល អោយកូនបៅដោះ លុះបានឃើញអ្នកក្លែងភេទនោះហើយ ក៏នឹកថាលោកសង្ឃបរិសុទ្ធ ទើបបីកូនចុះទៅថ្វាយបង្គំសួរថា «ព្រះករុណាម្ចាស់ និមន្តមកពីវត្តណា ត្រូវការរកអ្វីព្រះគុណ? ចៅពាលឆ្លើយទៅថា: «ចំរើនពរអាត្មាភាពមកពីវត្តក្រោមមករកបិណ្ឌបាតទៀនធូបយកទៅរៀនសមណធម៌ញោម អ្នកភូមិនេះគេទៅណាអស់ បានជាស្ងាត់ម្ល៉េះ?» ករុណាម្ចាស់គេទៅច្រូតស្រូវអែស្រែអស់ហើយលោកម្ចាស់។ អោ! ដូច្នោះហ:ញោម ចុះញោមអែងមិនទៅច្រូតស្រូវនឹងគេទេ? អោ! ករុណាម្ចាស់ខ្ញុំម្ចាស់នេះទៅច្រូតកាត់នឹងគេអែណាបាន កូនតូចនេះវាចេះតែឈឺមិនឈប់សោះឡើយ ចេះតែយំដាក់ពីដៃមិនរួចសោះ ព្រះករុណាម្ចាស់។ ចំរើនពរ ចុះវាឈឺយ៉ាងណាកូនញោមនោះ? ករុណាម្ចាស់អាការជំងឺនោះកំណត់មិនបានជួនកាលវាគ្រុនក្ដៅក្រហាយទៅ ជួនណាវាកើតជាស្កន់ជាន់គ្របបាត់ដង្ហើមទៅម្ដងៗ ក៏មាន ករុណាម្ចាស់។ អោ! អាណិតវាពេកណ៎ាញោម ជំងឺយ៉ាងនេះ គេហៅថា ស្កន់ខ្លាវាជាន់ណ៎ាញោម ម្ដេចមិនរកគ្រូពេទ្យអោយគេមើលគ្នាទៅ បណ្ដោយអោយឈឺយ៉ាងនេះ ជំងឺនេះមិនមែនក្រទេ ល្មមរក្សាបាន កូនបងអាត្មាភាពម្នាក់វាឈឺយ៉ាងហ្នឹងដែរ អាត្មាមើលជាទៅ អិលូវធាត់ទ្រលុកៗញោម អោ! ស្ដាយកូនញោមនេះពេកណាស់ប្រុសផង គួរតែខំមើលរក្សាទៅអេះ។

ករុណាម្ចាស់គ្រូនោះបានអោយគេមើលក៏ច្រើននាក់ណាស់ហើយ បានគ្រាន់តែ២-៣ថ្ងៃ ក៏ត្រលប់ឈឺដូចដើមវិញ ករុណាម្ចាស់។ អោ!គ្រូមើលជំងឺកូនក្មេងនោះគ្រាន់តែស្តោះផ្លុំតែពីក្រៅធ្វើម្តេច នឹងជាដាច់រោគស្អន់ខ្លានេះបាន តោងមើលដោយអុបទេសទើបជាដាច់ញោម អាត្មាចេះខ្លះដែរតែអាត្មាដែលមកនេះដោយមានកិច្ចរកទៀនធូបបានហើយ ក៏នឹងអាលទៅរៀនសមណធម៌ បើនៅជិតវត្តអាត្មាទៅរ៉ា នឹងជួយសង្គ្រោះមើលយកបុណ្យខ្លះ។

អែនាងមេម៉ាយនោះ  លុះលឺថៅពាលពោលពាក្យដូច្នោះហើយ  ក៏សំគាល់ថា  ជាលោកអ្នកចេះមើលជំងឺមែនទែនទើបនិយាយអង្វរថា ព្រះករុណាម្ចាស់ បើលោកម្ចាស់ចេះ អែត្រង់ទៀនធូបដែលលោកម្ចាស់ត្រូវការនោះមិនជាប៉ុន្មានទេ ខ្ញុំករុណា ថ្វាយខ្លួនជាញោមអុបដ្ឋាក  បវារណាលោកម្ចាស់  សូមកុំអោយលោកម្ចាស់ព្រួយព្រះហរិទ័យឡើយ។ អែថៅពាលនោះ បានអោកាសហើយក៏ឆ្លើយថា «ចំរើនពរធ្វើម្តេចអែងជាសង្ឃកំពុងសត្វ កាលបើឃើញញាតិញោមកើតវិបត្តិ តោងកាត់ធុរៈខ្លួនសិនចុះ ថាហើយក៏ឡើងទៅលើផ្ទះ។ អែនាងមេម៉ាយក៏រៀបទីអាសនៈដ៏សមគួរ អោយថៅពាលអង្គុយ ហើយបៀកស្លាម្លូរបារីដាក់ពានប្រគេនថៅពាល ថៅពាលក៏បង្គាប់អោយនាងរៀបទៀន៥ ធូប៥ ឆ្នាំងថ្មីមួយនិងសំពត់ស១ចំអាមទាញយន្តបិទមាត់ឆ្នាំង ហើយថៅពាលថា «ញោម ទីភូមិនេះមានត្បាល់ក្បឿងដែរឺទេ? «ករុណាម្ចាស់ ក្បាល់ក្បឿងខ្ញុំករុណាមាន នៅខាងកន្សែផ្ទះអែនោះ។ «អើញោមបើដូច្នោះញោមយកកូននិងគ្រឿងទៀនធូបអស់នេះទៅអែរោងក្បឿងអាត្មានឹងរៀបពិធីក្បឿង»។

នាងមេម៉ាយក៏បីកូនកាន់យកទៀនធូបអស់នេះទៅអែរោងក្បឿង ហើយថៅពាលយកទៀនធូប អុជតាំងពិធីនៅមាត់ត្បាល់ ហើយវាបោសទីនោះស្អាតល្អពុំអោយមានឈើព្រៃនៅខាងត្បាល់ ទើបវាហៅអោយយកកូនខ្ចីនោះ មកតាំងខាងនាទីពិធី ហើយវាថា ញោមអែងទៅជាន់ចុងក្បឿងអោយវាឡើង ជាន់ដាក់ជន្លួ បាន៣ដងជាអុបកិច្ចអាត្មានឹងសែកព្រះគាថាស្រូបយកព្រលឹងខ្លាចេញពីរូបកូន បញ្ចូលដាក់ក្នុងឆ្នាំងយន្តហើយយកទៅបណ្តែតទឹកចោល ដើម្បីកុំអោយព្រលឹងខ្លាវាមកបៀតបៀនបានទៀតឡើយអែនាងមេម៉ាយក៏ជឿតាម ទើបទៅជាន់ចុងក្បឿងឡើង អែថៅពាលវាយកកូននោះដាក់ទៅក្នុងត្បាល់ហើយវាដកឈើទ្រនល់ដែល ទល់ក្បឿងនោះ បោះគ្រវែងចោលទៅឆ្ងាយអំពីត្បាល់ ហើយ

វាដើរចេញពីទីពិធីនោះប្រាប់ទៅថា ញោមប្រុងជាន់អោយជាប់កុំប្រែហាសក្រែងរបូតជើងធ្លាក់ទៅត្រូវកូន ចាំអាត្មាទៅយកថង់យាមឆាន់ស្លាមួយរំពេច សូមមកទល់អោយវិញ ថាហើយចៅពាលក៏ឡើងទៅលើផ្ទះ តាំងរើរកបស់ទ្រព្យមាសប្រាក់កែវកង សំពត់អាវស្បៃហើយវាវេចជាសំពាយធំ តាំងស្ពាយពីលើផ្ទះរត់ទៅកាន់លំនៅវាហោង។

អែនាងមេម៉ាយឃើញចៅពាលជញ្ជូនយកទ្រព្យសម្បត្តិខ្លួនដូច្នោះហើយ ក៏ហៅអោយគេជួយ ក៏ពុំមានអ្នកណាមួយលឺឡើយ ព្រោះផ្ទះនោះនៅដាច់អំពីគេ ម្លោះហើយនាងមេម៉ាយក៏អន្ទះអន្ទែង នៅចុងក្លៀងនោះអែង បើនឹងលែងក្លៀងចេញទៅ ខ្លាចធ្លាក់ទៅត្រូវកូនដោយចិត្តមាតាតែងទន់ទោរចុះទៅកាន់កូនអាត្មាជាធម្មតា ការដែលសោកស្តាយទ្រព្យសម្បត្តិក្រៅក៏ជាមធ្យម អែសេចក្តីដែលលោកអាណិត កូននោះលើកលែងសម្បត្តិខាងក្រៅ នាងមេម៉ាយក៏នៅច្រងាងដូចបុគ្គលគេចងភ្ជាប់រតែខ្លួនក៏ពុំរួច លុះដល់ពេលល្ងាច ទើបមានគេដើរមក ទើបអោយគេទល់ចន្ទល់ ក្លៀងយកកូនបាន។

អាសូវនាងមេម៉ាយកាយជាប់ក្លៀង ព្រោះអាចោរសំពត់លឿងវាបញ្ឆោត សែនក្តួលសែនក្តៅក្រេវក្រោធនឹងលោតទៅតាមចាប់អាចោរ ក្រែងក្លៀងត្រូវកូនសូនជីវិត ដោយចិត្តមាតាតែងទន់ទោរ តែមានអារម្មណ៍អោយខឹងឃោរ នឹងចោល បង់កូននោះពុំមាន។ និទាននេះមានដំណាលក្នុងក្បួនសៀម។

ស. សួរថាអាការមនុស្សពាលដែលវាសំដែងមកនោះ តើមានយ៉ាងណាខ្លះទាន?

គ. តបថា អែមនុស្សពាលដែលសំដែងអាការចេញនោះមានច្រើនប្រការណាស់ ខ្លះវាប្រើកិរិយាសង្រួមហួសប្រមាណ ខ្លះវាព្យូហ៍ពាក្យបំភ័យ ខ្លះពោលអួតវិជ្ជាចំណេះ ដែលខ្លួនវាពុំមានតែបើមានប្រាជ្ញាពិចារណា តាមអាការវាក៏គង់យល់ខ្លះមិនខាន។

# តំរាពាលសង្រួមហ្វសប្រមាណ

ដូចនិទានពីតាបស១រូប ទៅតាំងអាស្រមកុដិនៅខាងជាយព្រៃ១ នៅទៀបជនបទនោះមានអុបាសកម្នាក់ជាអ្នករាប់អានតាបសនោះ បានថ្វាយខ្លួនជាអ្នកអុបដ្ឋាកជាអ្នកបំរើ។ អែតាបសនោះតែងចូលទៅកាន់ត្រកូលនោះរឿយៗ លុះនៅយូរមក អុបាសកនោះយកប្រាក់១ហឹបទៅផ្ញើទុកនឹងតាបស។ អែតាបសក៏អោយអុបាសកកប់ហឹបប្រាក់ទុកក្នុងទី១ ដ៏សមគួរខាងទីអាស្រមនោះអែង ដល់យូរបន្តិចមក តាបស នោះកើតលោភចេតនា ទើបគិតថា អាត្មាអញនេះមកបួសខំប្រព្រឹត្តរក្សាសីល ក៏យូរឆ្នាំណាស់ហើយ មគ្គក៏មិនបានដល់  ផលក៏មិនបានសំរេចទាំងឈានទៀតក៏ មិនកើតម្តងសោះ បើដូច្នេះគួរតែអញសឹកចេញចាកសិក្ខាទៅជាយរាវាសវិញ គិតប្រកបការរកស៊ីយល់ជាប្រសើរជាង អែប្រាក់ដែលអុបាសកគេផ្ញើនោះ អញនឹងលួច យកទៅធ្វើជាដើមទុន ប្រកបការខាងផ្លូវលោកិយបានហើយ តែនឹងលួចយកទៅអិលូវនេះ អុបាសកជាម្ចាស់គេនឹងតាមតវ៉ាចោទថា អាត្មាអញលួច បើដូច្នេះ មានតែគិតលួចជាការបង្វែងដាន កុំអោយម្ចាស់គេនោះសង្ស័យនឹងខ្លួនអញបាន កាលបើតាបសគិតយល់អុបាយ១ដូច្នេះហើយ ទើបកកាយយកហឹបប្រាក់អំពីទីនោះ នាំទៅកប់ទុកទីដទៃ ដើម្បីមិនអោយម្ចាស់ប្រាក់សង្ស័យនឹងខ្លួន លុះកប់លាក់ហឹបប្រាក់ នោះហើយតាបសក៏រៀបគ្រឿងបរិក្ខារដាក់សំពាយស្ពាយដើរទៅកាន់ផ្ទះអុបាសក

អែអុបាសក បានយល់តាបសមកដូច្នេះហើយក៏រៀបទីអាសនៈដ៏សមគួរ ហើយ និមន្តតាបសឡើងទៅលើគ្រឹះស្ថានវន្ទាធ្វើបដិសណ្ឋារៈសួរទទួលដោយសេចក្តីរាប់អាន។ អែតាបសនិយាយថាៈ «ចំរើនពរ អាត្មាភាពមកលាញោមទាំងអស់គ្នា នឹងទៅនៅព្រៃព្រះហិមពាន្តហើយ ត្បិតទីលំនៅសព្វថ្ងៃនេះ ជាទីនៅជិតទៀបស្រុក មនុស្សម្នាទៅមកមិនដាច់ នាំអោយកង្វល់រវល់នឹងការលោកិយច្រើនណាស់ រកអោកាសនឹងចំរើនភាវនាពុំបាន ១ទៀតអែរឿងប្រាក់ញោមដែលផ្ញើនោះ អោយញោមទៅយកជងចុះ អាត្មាទៅហើយក្រែងមានអន្តរាយជាខាងក្រោយ ញោមកុំមៃថាអាត្មាឡើយ»។ អែអុបាសកនោះក៏ឆ្លើយថា  «មិនអីទេ ព្រះករុណារឿងប្រាក់  ដែលកប់លាក់ទុកនោះចំពោះដឹងតែលោកម្ចាស់  និងខ្ញុំករុណាតែពីរនាក់  ប៉ុណ្ណោះអែងអ្នកអែណានឹងបានដឹងលឺផងជា៣-៤នាក់ពុំមាន បើលោកម្ចាស់ចង់ទៅនៅព្រៃហិមពាន្ត

ក្នុងថ្ងៃណា ក៏សូមនិមន្តទៅចុះរឿងប្រាក់នោះចាំខ្ញុំរួចចុះរ:រល់ថ្ងៃណាសឹមខ្ញុំទៅ យក។ អែតាបសក៏ឆ្លើយថា «ចំរើនពរ អញ្ជើញទៅយកចុះ» ថាហើយក៏លាត្រកូលនោះចេញទៅ កាលចុះទៅដល់មាត់ជណ្ដើរ តាបសក៏កាន់យកស្បូវដែល ប្រក់ផ្ទះនោះមួយសរសៃ ហើយសៀតជាប់នឹងជដា គឺផ្នួងសក់ដើរទៅដល់មាត់ច្រកផ្លូវ ហើយវិលត្រលប់មកវិញលើក យកកំណាត់ស្បូវនោះ ជូនទៅអុបាសកហើយថា «ញោមអើយអាត្មាភាពសូមទោសញោមផងចុះ ត្បិតអាត្មាពុំបានក្លែង លួចកំណាត់ស្បូវនេះទេ គឺវាជាប់ទៅនឹងផ្នួងជដានៃអាត្មាអាត្មាក៏ពុំដឹងសោះលុះតែដើរទៅដល់ក្រៅបង ស្រាប់តែឃើ ញស្បូវនេះវាធ្លាក់ពីជដាមក ទើបអាត្មាកើតសេចក្ដីភិតភ័យដោយសីល ក្រែងសៅហ្មង ហេតុនេះទើបយកមកជូន ញោមវិញ សូមញោមមេត្តា អត់ទោសអាត្មាចុះ»។

អែអុបាសកនោះ លុះលឺពាក្យជដិលកោងនិយាយជូនកំណាត់ ស្បូវដូច្នេះហើយ ក៏សំគាល់ថា «លោកតាបសនេះមាន សីលពិសេស» ទើបតបទៅថា: «បពិត្រព្រះករុណាម្ចាស់ កុំមានហរិទ័យរង្កៀសឡើយ យើងខ្ញុំពុំមានចិត្តសង្ស័យ នឹងសី លលោកម្ចាស់ទេ ចូរលោកម្ចាស់និមន្តទៅតាមសប្បាយចុះ»។

គ្រានោះ ព្រះពោធិសត្វជាម្ចាស់យើងនេះ អន្ទោលជាតិកើតជានាយឈ្មួញ១នាក់ បានទៅជួញដល់ទៅស្រុកនោះលុះ ដើរទៅបានលឺតាបសជូនកំណាត់ស្បូវ ដែលខ្លួនកាន់យកដោយអុបាយកោងដូច្នេះហើយក៏យល់ដោយប្រាជ្ញា ជ្រាបថា តាបសនេះ មានបើលួចយកទ្រព្យអ្វីៗ របស់អ្នកផ្ទះនេះមិនខានឡើយ ទើបពោធិសត្វដណ្ដឹងសួរ ទៅអុបាសកនោះថា «អ្នកអែងមានផ្ញើទុកដាក់របស់អ្វី នឹងតាបសនេះខ្លះដែររឺទេ?» អុបាសកនោះប្រាប់ថា ខ្ញុំបានផ្ញើប្រាក់១ហឹបនឹងលោក។ ពោធិសត្វថា «អោ! បើ ដូច្នោះប្រាក់អែងនោះ វិនាសដោយដៃលោកជីតុនអ្នកអែងប្រាកដហើយ ប្រាក់១ហឹបនោះ លោកជីតុនអ្នកអែងលួចយកទៅហើយ ចូរអ្នកអែងទៅតាមចាប់ខ្លួនអោយទាន់ក្នុងកាលអិលូវនេះ។

អែអុបាសកនោះជាមនុស្សអិតប្រាជ្ញា ក៏ឆ្លើយតបថា: «លោកជីតុនខ្ញុំនេះ លោកមានសីលវិសេសពេកណាស់ លោក នឹងអាចហ៊ានលួចប្រាក់នោះអែណាបាន តែត្រឹមកំណាត់ស្បូវ១សរសៃ ដែលជាប់ទៅនឹងជដាសក់របស់លោកម្ដេច លោកក៏ពុំហ៊ានកន្លង លោកនាំយកមកអោយវិញ ហេតុនោះនឹងថាលោកលួចប្រាក់ខ្ញុំអែណាក៏បាន។ ពោធិសត្វតបថា

«អោ! អ្នកអែងមិនស្គាល់អាការពាលទេតើ! នែអ្នក ក៏អែសីលអទិន្នាទាននឹងដាច់នឹងសៅហ្មង ព្រោះកំណាត់ស្បូវ១ សរសៃនោះវីអ្វី នេះអែងហើយជាអាការរបស់មនុស្សយកសក់បាំងភ្នំ បន្លំដាន លួចប្រាក់អ្នកអែងពិតហើយ បើអ្នកអែងមិនជឿ អញ្ជើញទៅមើលប្រាក់អ្នកចុះ ដែលផ្ញើទុកនោះ ជានៅដូចដើមវីដូចម្តេចទៅ ចូរទៅអោយឆាប់ ទាន់តាបសគាត់មិនទាន់ទៅឆ្ងាយ។ អែអុបាសកនោះក៏យល់តាម ទើបនាំពោធិសត្វទៅអាស្រមនៃតាបស ទៅមើលទីដែលកប់ប្រាក់នោះ ឃើញអាចម៍ដីខ្វាយរាយពាស ទើបកកាយទៅខាងក្រោមក៏ពុំឃើញហឹបប្រាក់នោះឡើយ។ អុបាសកក៏រឹតតែជឿពាក្យពោធិសត្វក្រៃពេក ទើបនាំពោធិសត្វរត់ទៅតាមតាបស បានទាន់នាកណ្តាលផ្លូវ ហើយក៏ចាប់ខ្លួនតាបសនោះមកសាកសួរថា ប្រាក់យើងដែលផ្ញើនោះបាត់អស់ទៅហើយ កាលយើងមកកប់ទុកនោះ ពុំមានអ្នកណា១អាចដឹងទេ គឺដឹងតែប្រស្តែងអែង និងរូបយើងពីរនាក់ប៉ុណ្ណោះទេ អិលូវបាត់ពីទីនោះទៅ នឹងថាអ្នកអែទៀតណាមកលួចនោះក៏មិនបាន គឺប្រស្តែង អែងលួចពិតហើយ ចូរអ្នកប្រាប់យើងដោយពិតចុះបើពុំប្រាប់យើង យើងនឹងវាយអោយស្លាប់អិលូវនេះអែង។ អែជដិលកោងនោះក៏ភិតភ័យខ្លាចសេចក្តីស្លាប់ ក៏ប្រាប់តាមដំណើរខ្លួនលួចបង្វែងទៅកប់ទុកនៅទីអែទៀត ហើយក៏នាំអុបាសកនោះ ទៅ យកហឹបប្រាក់ដែលខ្លួនលាក់ទុកនោះប្រគល់អោយដល់អុបាសកជាម្ចាស់ប្រាក់។ អែ អុបាសកក៏ទទួលយកហឹបប្រាក់ហើយតិះដៀលតាបសនោះដោយប្រការផ្សេងៗ ហើយបែរទៅសរសើរប្រាជ្ញានៃពោធិសត្វ ដោយអនេកប្បរិយាយ ទទួលពោធិសត្វទុកជាគ្រូអាចារ្យប្រដៅខ្លួនអំពីថ្ងៃនោះមក។

ចប់តំរាពាលសង្រួមហួស ប្រមាណ

ស. ឆ្លើយថាករុណាលោកគ្រូម្ចាស់ៗ សំដែងមកនេះខ្ញុំចូលចិត្តហើយ តែការដែល នឹងស្គាល់អាការកិរិយាមនុស្សពាលនោះក្រណាស់  ដូនមនុស្សពាលនោះ វាមានអំណាច និយាយបញ្ចុះបញ្ចូលអ្នកស្រុក   អ្នកស្រុកក៏នាំគ្នាជឿតាមពាលនោះទៅ ជូនជាមានអ្នកណា១ដឹងស្គាល់អាការកិរិយានៃមនុស្សពាល  នៅមិនប្រព្រឹត្តមិនជឿតាមគេៗ ក៏បៀតបៀនអ្នកនោះអែងថាជាមនុស្សឆ្កួតវិញដូច្នេះនេះលោកគ្រូនឹងប្រព្រឹត្តទៅយ៉ាងណា  នឹងអោយរួចអំពីពាលនោះបាន?។

គ. អោ!អែងថានោះត្រូវហើយ  ក៏វិស័យគេឆ្កួតពេញស្រុកហើយ អែងជាតែម្នាក់អែង  អែណាក៏នឹងបានតែតោងមើ

លកាល មើលសម័យ ពិចារណាមើលតាមអាការនោះផង ជាការពាក់ព័ន្ធដោយទោសរាជ រឺ ដោយទោសរាស្ត្រ គឺកើតមកជាមនុស្សត្រូវអោយស្គាល់ទោសពីរប្រការ គឺទោសរាជ១ ទោសរាស្ត្រ១ អែទោសរាជនោះ គឺពាលនោះអែងវាក្លែងតាំងខ្លួនជាអ្នកបុណ្យ ហើយអួតខ្លួនថា វាជាស្តេច ជាព្រះអង្គម្ចាស់ មាននាមថា ព្រះបាទធម្មិករាជជាដើម តាំងបញ្ចុះបញ្ចូលមហាជនកងទ័ព គិតក្បត់ម្ចាស់ផែនដីយ៉ាងនេះហៅថាទោសរាជ គឺទោសព្រោះតាំងខ្លួនជាស្តេច ថាបើអែងដឹងអាការហេតុដូចយ៉ាងថាមកនេះហើយតោងគិតវេះគេចចេញចាកទីនោះបង់ ទើបអាចរក្សាខ្លួនអោយសុខបាន។

អែទោសរាស្ត្រនោះ គឺពាលមានអំណាចក្តី អិតអំណាចក្តី វាប្រចុបប្រចែងក្លែងក្លាយ ប្រើអុបាយមាយានិយាយអួតកុហកថា វាចេះធ្វើហោរទាយ ចេះអង្គុយធមិ មើលហួយ មើលខ្មោច ចេះគ្រូមើលជំងឺ មើលស្តោះគ្រោះ បូជាគ្រោះជាដើម ហើយវានិយាយបំភ័យអោយអ្នកស្រុកបូជាផ្សេងៗ។ មនុស្សទាំងឡាយជឿពេញស្រុកហើយ តែអែងមិនជឿតាមគេ គេថាអែងឆ្កួត យ៉ាងនេះហៅថាទោសរាស្ត្រ។ តែបើពាលមានអំណាច វានឹងបៀតបៀន ហើយតោងប្រព្រឹត្តទៅតាមកិរិយាដូចតំរាថា «លោកប្រែតោងប្រព្រឹត្តតែចិត្តកុំប្រែតាមវា» គឺប្រព្រឹត្តតែកិរិយាក្រៅទៅចុះ ព្រោះការទាល់ ដូចមាននិទានរឿងថៅសនជាបែប។

# រឿងតាថេន និង សិស្សបីនាក់

អែរឿងថៅសននោះ ដើមឡើយមានសាមេណរ១អង្គ អ្នកស្រុកគេតែងហៅ លោកតាថេនលោកតាថេននោះជានេន ខ្ជីខ្ជា លួចមាន់វត្តស្ងោរផឹកស្រាស៊ីបាយល្ងាចតែរឿយៗ មានមនុស្ស៣នាក់រួមចូលផឹកស៊ីជាមួយផង។ លុះនៅយូរមក តាថេន រកប្រាក់នឹងទិញស្រាពុំបាន ហើយគិតក្រែងនៅយូរទៅអ្នកស្រុកគេដឹងថានេនផឹកស្រាគេនឹងបេណ្តញបំបរចោកអារាម ទើបនិយាយពិគ្រោះគ្នានឹងមនុស្សទាំង៣ នាក់នោះថាយើងនៅក្នុងស្រុកធំនេះ អត្តខាត់ប្រាក់ចាយណាស់ អុបាសកអុបាសិកា ញោមវត្តនេះ  គេក៏ពុំមានសទ្ធាធ្វើបុណ្យធ្វើទាននឹងយើងឡើយ។  បើដូច្នេះគួរយើងចេញទៅស្រុកក្រៅ ដើរកកៃខែកុហកបញ្ឆោតអ្នកស្រុកស្រែចំការ ដោយអុបាយកលផ្សេងៗ គឺអញធ្វើជាលោកធុតង្គរុក្ខមូលថៅ អែង៣នាក់ធ្វើជាកូនសិស្សអុបដ្ឋាកដើរតាមក្រោយ ដើរនិយាយបញ្ចុះបញ្ចូលបបួលពួកអ្នកព្រៃអោយគេជឿថា អញវិសេស គេក៏និមន្តធ្វើបុណ្យទាន បានចតុប្បច្ច័យ ហើយសូមយើងកៃខែទិញបាយ ទិញស្រាផឹកទៅតាមកាល។

អែមនុស្សទាំង៣នាក់នោះក៏យល់ព្រមតាមតាថេនក៏រៀបរកឆ័ត្រមុងធុតង្គ នូវគ្រឿងបរិក្ខារបានព្រមហើយទើបនាំមនុស្ស៣នាក់នោះ ចេញចាកស្រុកធំ ដើរទៅកាន់ស្រុកលើតាថេនក៏ក្លែងខ្លួនជាលោកសង្ឃធុតង្គដោយព្រៃ ដល់វេលាព្រឹកក៏ចូលទៅបិណ្ឌបាតក្នុងស្រុកតាមលំដាប់ផ្លូវ អែបណ្តាមហាជន អ្នកស្រុក ក្រៅកាលបើបានឃើញតាថេននោះហើយក៏នឹកស្មានថាជាលោកសង្ឃរុក្ខមូលដោយសុចរិត  ទើបនាំគ្នាដាក់បាតប្រគេនចតុប្បច្ច័យផ្សេងៗ  អ្នកខ្លះនិមន្តឆាក មហាបង្សុកូល អ្នកខ្លះនិមន្តដារឆាន់ធ្វើបុណ្យផ្សេងៗតាមសទ្ធាអ្នកកាន់ព្រះ ពុទ្ធសាសនា។ តាថេនបានលាភសក្ការៈហើយ ក៏ធ្វើជាសង្រួមអិន្ទ្រីយស្រគត់ស្រគំ ពុំសូវនិយាយស្តីអ្វីច្រើនឡើយ។ អែមនុស្ស៣នាក់នោះតែទៅដល់ទីណាវាក៏នាំនិយាយសរសើរអួតគុណតាថេន ប្រាប់អ្នកស្រុកនោះថា លោកគ្រូយើងនេះ លោកវិសេសខាងផ្លូវក្នុងពេកណាស់ ទាំងទឹកមន្តក៏ពូកែចេះទាំងឃឹតមើលហួយ មើលប៉ោក៏ឆុតឆាប់ តែលោកជាអ្នកសណ្តោស មិនមានចិត្តលោភោទេបើអ្នកណាត្រូវចិត្តលោក លោកក៏ប្រោសអោយទានបានសំរេចប្រយោជន៍គ្រប់ប្រការ ពួកយើង៣នាក់ក៏អុស្សាហ៍ដើរតាមលោកទាំងម្ល៉េះនេះ  ព្រោះឃើញសិល្បវិជ្ជាការនោះមែនទែនណាស់។  អែពួកមហាជនទាំងឡាយកាលបើបានស្តាប់

ពាក្យអ្នកទាំង៣នាក់ស្រដីអួតតាថេនដូច្នោះហើយក៏ជឿតាម  ទើបនាំគ្នានិមន្តតាថេនសូត្របូជាព្រះគ្រោះ ខ្លះសូមទឹកមន្ត ខ្លះសូមខ្សែក ខ្សែចង្កេះខ្លះ តាថេនក៏បានលាភសក្ការៈបរិបូណ៌ដោយ ពួកអ្នកក្រៅរាប់អាន តែដល់ពេលយប់ស្ងាត់ចៅ៣នាក់ វាទៅលួចទិញស្រាទិញបាយមកលៀងគ្នាក្នុងព្រៃតាមវិស័យកិរិយាពាល។

អែតាថេននិងអ្នក៣នាក់  វាប្រព្រឹត្តការកោងយ៉ាងនេះរៀងៗទៅតាមផ្លូវ។  លុះថ្ងៃ១ តាថេននាំគ្នាទាំង៣នាក់ដើរទៅដល់ភូមិគោក១ ទើបចូលទៅកាន់ភូមិនោះ ហើយទៅអង្គុយក្រោមម្លប់ដើមស្វាយខាងជើងភូមិ។ អែចៅ៣នាក់វានាំគ្នាចូលទៅក្នុងភូមិនិយាយឃោសនាប្រាប់អ្នកស្រុកថា លោកធុតង្គនិមន្តមកគង់នៅខាងជើងភូមិនោះអែង បើបងប្អូនត្រូវការប្រាថ្នាការអ្វីៗក៏អញ្ជើញយកទឹកតែ ស្លូរស ស្លាបារីទៅប្រគេនលោកចុះ លោកនិមន្តមកនេះ គឺមកចង់ប្រោសសត្វហើយ អ្នកណាចង់បានខ្សែកខ្សែចង្កេះ ទឹកមន្តការពាររោគអាសន្នកម្មផ្សេងៗ ក៏សូមអញ្ជើញទៅរកលោកអោយឆាប់ចុះ។ អែបណ្តាមហាជនប្រុសស្រីនៅទីភូមិនោះលុះលឺថាលោកធុតង្គរុក្ខមូលវិសេសមកដូច្នេះហើយ ខ្លះក៏បានស្លាបារី ខ្លះក៏បានទឹកក្តៅ ទឹកត្រជាក់នាំគ្នាទៅរកតាថេន ដល់ហើយក៏ថ្វាយបង្គំសួរទទូលបដិសណ្ឋារៈប្រគេនទឹកស្រង់ទឹកឆាន់ ស្លាម្លូភេសជ្ជៈតាមសទ្ធា ហើយសំពះសួរថា ព្រះករុណាម្ចាស់និមន្តមកពីស្រុកណាព្រះករុណា។ តាថេនឆ្លើយថា «ចំរើនពរអាត្មាភាពនេះនៅក្នុងក្រុងចេញមកធុតង្គយូរខែហើយ ទើបតែថ្ងៃនេះមានហេតុជាការមិនស្រួលនៅភូមិស្រុកញាតិញោមនេះ បានជាអាត្មាភាពខំអុស្សាហ៍ដើរមកនេះ»។ អែពួកអ្នកស្រុកនោះលុះលឺតាថេនថា ដូច្នេះហើយ ក៏កើតសេចក្តីសង្ស័យឡើងគ្រប់គ្នា ទើបនាំគ្នាសួរតបថា «ករុណាម្ចាស់,មានពុទ្ធដិកានេះយល់ប្លែកពេកណាស់» ចុះលោកម្ចាស់ យល់ហេតុភូមិ យើងនេះមិនស្រួលយ៉ាងណា? តាថេនថា «ញាតិញោមអើយ, អាត្មាអង្គុយធម៌យប់មិញនេះ ក៏ឃើញហេតុអន្តរាយ នឹងកើតមានដល់ញាតិញោម ក្នុងភូមិនេះទាំងអស់គ្នា គឺឃើញថា ភូមិនេះនៅតែ៧ថ្ងៃទៀត នឹងមានអសនីបាត គឺរន្ទះបាញ់មកត្រូវ ភូមិនេះដល់នូវសេចក្តីវិនាសសូន្យទាំងភូមិជាម្តង អាត្មាគិតអាណិតដល់ញាតិញោមរាល់គ្នាណាស់ បានជាខំអុស្សាហ៍មកនេះ ប្រាថ្នានឹងប្រាប់សេចក្តីនោះអោយញាតិញោមបានដឹងខ្លួនជាមុន  ថាបើញោមអែណាចង់អោយរួចអំពីកាឡកិណីសេចក្តីវិនាសនោះមានតែរើផ្ទះសំបែងចេញអំពីទីចាស់ទៅតាំងនៅភូមិក្រៅជាថ្មីទៀត

នោះទើបបានផុតភ័យអំពី អសនីបាតនោះបាន»។

អែបណ្តាមហាជនទាំងឡាយនោះ លុះលឺតាថេនថាដូច្នេះហើយ ក៏កើតសេចក្តីភិតភ័យទាំងអស់គ្នា ទើបតបថា «សូមទានករុណាម្ចាស់ បើដូច្នេះសេចក្តីភ័យនោះនឹងមានដល់យើងខ្ញុំហើយ តែថាការដែលថារើផ្ទះសំបែងអំពីភូមិនេះចេញទៅនោះ យល់ថាជាការលំបាកណាស់បើដូច្នេះករុណាម្ចាស់ នឹងមានអុបាយកលល្មមអុបទេស កែខៃសេចក្តីអន្តរាយអំពី រន្ទះនោះជាបានខ្លះរឺទេ?» អោ! ញាតិញោមចង់គិតកែខៃអុបទេសនោះ ចាំអាត្មាអង្គុយធម៌មើលសិន ថាហើយ តាថេនតាំងអុជទៀនធូប ហើយតាំងសមាធិអង្គុយ ធ្មេចភ្នែកបានតិច ក៏បើកភ្នែកហើយថា បានញោម តែត្រូវខាតទុនខ្លះទើបអាចធ្វើបាន។ ករុណាម្ចាស់មិនអីទេ ទោះបង់ខាតធនធានប៉ុន្មានៗ ក៏មិនថាដែរ ធ្វើម្តេចអែងដល់នូវសេចក្តីវិនាសហើយ សូមនិមន្តលោកគ្រូម្ចាស់បង្គាប់ចុះ។ តាថេនក៏ធ្វើជាមាយាហើយប្រាប់ថា អោ! ញាតិញោមអើយ អាត្មានេះជាសង្ឃផង នឹងបង្គាប់បញ្ជាទៅក៏ដូចជាមិនគួរ នឹងភេទអែងជាសមណៈនោះសោះ ត្បិតភ្លើងរន្ទះនោះតាមបាលីថា អសនីគឺថាអសុរាប្រែថាយក្ខខ្មោចនោះវាគាប់ចិត្តតែនិងស្រា បាយសាច់ញាំភ្លាមាន់ស្ងោររៀបបូជាពលិការវា ហេតុនោះបានជាអាត្មាទាស់ណាស់ ព្រោះអែងជាលោកសង្ឃ។ ករុណាម្ចាស់ កុំព្រួយព្រះហរិទ័យឡើយនិមន្តបង្គាប់ចុះ យើងខ្ញុំនឹងធ្វើតាម។ តាថេនបានអោកាសដូច្នេះហើយក៏អោយធ្វើរោងពិធី១ខ្នង នៅក្រៅភូមិហើយអោយធ្វើរាជវ័តិ ទង់ ឆ័ត្រ ស្លាធម៌ បាយសី ជមចារ គ្រឿងចំអាបបង្អែមផ្សេងៗ យកទៅតាំងនៅរោងពិធី។

អែមនុស្សទាំងឡាយ ក៏នាំគ្នាធ្វើតាមពាក្យតាថេននោះសព្វប្រការ អែតាថេនក៏នាំគ្នា៣នាក់ចូលទៅក្នុងរោង ហើយយកអំបោះចងព័ទ្ធសីមា៧ជាន់ហើយប្រាប់អ្នកស្រុកថា ញាតិញោមទាំងអស់នេះ សុទ្ធសឹងជាមនុស្សមានគ្រោះធំត្រូវតែនៅក្រៅរោងពិធីនេះ តាថេនថាហើយទើបសរសេរសំបុត្របិទនៅមាត់ទ្វារនោះថា កុំអោយនរណាចូលក្នុងរោងពិធីនេះឡើយ ថាបើនរណាកាត់អំបោះសីមាកន្លងចូលដល់ ក្នុងរោងហើយអ្នកនោះនឹងទៅជាឆ្កួតឈឺស្លាប់កើតវិបត្តផ្សេងៗ។ បណ្តាអ្នកស្រុកធ្វើតាមតាថេនហាមទាំងអស់ នាំគ្នាហាមកូនចៅក្មេងតូចធំ កុំអោយចូលទៅក្នុងរោងពិធីនោះ។

អែតាថេនបានអោកាសស្ងាត់ហើយ ក៏នាំគ្នាទាំង៣នាក់ ស៊ីបាយផឹកស្រាតាមអំពើពាល លុះស្រវឹងស្រាខ្លាំងក៏តាំងនិយា

យកោកៗ ប្រកែកគ្នាទៅវិញទៅមកគឹកកងក្នុងរោង លុះដល់នៅបានពីរបីថ្ងៃមានក្មេងប្រុសម្នាក់អាយុ ១៤ រឺ១៥ឆ្នាំ ឈ្មោះថៅ សន ក្មេងនោះវាទៅឃ្វាលក្របីនៅវាលស្រែ។ ដល់ពេលថ្ងៃល្ងាចត្រជាក់ ថៅសន វាដេញក្របីទៅផ្ទះបរទៅខាងរោងពិធីនោះ បានលឺសំលេងថៅពាលទាំង៤នាក់ផឹក ស៊ីប្រកែកគ្នាកោកកាកដូច្នេះហើយ ថៅសនគិតថាសំលេងយ៉ាងនេះ ទំនងជាមនុស្សស្រវឹងស្រា យ៉ាងលោកសង្ឃនោះផឹកស្រាទេដឹង បើដូច្នេះគួរអញលបទៅមើលអោយជាក់ច្បាស់ ទោះវាឆ្កួតរឺឈឺចាប់យ៉ាងណាក៏តាមចុះ អញប្រថុយលបមើល គិតហើយក៏ដើរលបចូលទៅដល់ប្របជញ្ជាំងរោង ហើយលួចបើកស្លឹកត្នោតដែលបាំងនោះគន់មើលទៅក្នុងរោង ក៏ឃើញថៅពាលទាំង៤នាក់ អង្គុយជំកងគ្នាស៊ីបាយ ផឹកស្រាដោយអំពើពាល។ ថៅសនឃើញច្បាស់ហើយក៏នឹកថា យីអាដែងអស់នេះ ផឹកស្រាស៊ីបាយល្ងាចទេតើពុទ្ធោៗ អោ ម៉ែអូវអញទៅជឿអាពួកនេះឆ្កួតទទេ ទាំងអ្នកស្រុកក៏ជឿចុះចូលវា អោយវាបញ្ឆោតអស់ខ្លួនមែនហើយ បើដូច្នេះគួរអញ ទៅប្រាប់ម៉ែអូវអោយគាត់បានដឹងផងចុះ គិតហើយក៏ដើរថយចេញម្នីម្នារត់ត្រង់ទៅផ្ទះ បានឃើញម្ដាយនៅលើផ្ទះ ថៅសនក៏ប្រាប់ម៉ែ ម៉ែ! ម៉ែអែងទៅជឿអីលោកសង្ឃធុតង្គនោះមិនពិតជាលោកសង្ឃល្អទេ វាក្លែងក្លាយទេម៉ែ ខ្ញុំបានឃើញវាផឹកស្រា ស៊ីបាយល្ងាចអំបាញ់មិញនេះអែង។

អែនាងជាម្ដាយបានលឺពាក្យកូនប្រាប់ដូច្នេះហើយ ក៏ពុំមានសតិសម្បជញ្ញៈ នឹងត្រិះរិះអោយច្បាស់លាស់ដោយជឿពាក្យតាថេនថា នរណាកាត់សីមាចូលក្នុងរោងពិធីលោក អ្នកនោះនឹងឆ្កួតប្រាកដ ទើបកើតភិតភ័យតក្កមាហើយសួរថា «ថៅសន អែងចូលទៅក្នុងរោងពិធីលោករឺអី?» ថៅសនថា «បាទខ្ញុំបាទលួចលបចូលទៅឃើញ វាកំពុងតែផឹកស៊ីទាំង៤នាក់ណាម៉ែ» ម្ដាយថា «អោ កូនអើយ លោកបានហាមទាំងអស់គ្នាថា កុំអោយនរណាចូលទៅក្នុងសីមារោងពិធីលោក អិលូវកូនអែងចូលទៅនោះ ត្រូវដូចលោកថា អ្នកណាចូលហើយអ្នកនោះនឹងឆ្កួតមិនខាន អិលូវអែងឆ្កួតហើយ តើកូនគួរអីទៅថាលោកសង្ឃផឹកស្រានោះ លោកជាអ្នកដើរធុតង្គវិសេសណាស់។ ថៅសនប្រកែកថា «ម៉ែអែងមិនជឿខ្ញុំរឺ ខ្ញុំបានឃើញច្បាស់នឹងភ្នែកហើយ អាដែងទាំង៤នាក់នោះ វាមកក្លែងបញ្ឆោតគេយកលាភទេ អ្នកណាទៅជឿវាក៏គង់នឹងខូចខ្លួន។ អែនាងម្ដាយមិនស្ដាប់ ចេះតែថា អាអែងចូលក្នុងសីមាលោកវាឆ្កួតមែនហើយ។ អែបណ្ដាពួក

ញាតិនៅជិតខាង បានលឺចៅសននិងម្តាយប្រកែកគ្នាដូច្នេះហើយសឹងឆោឡោឡើងទៅសួរថា ម្តេចចៅសនវាចូលទៅក្នុងសីមាលោកនោះអ៊ីអី? នាងម្តាយក៏ប្រាប់ទៅថា អើអែងអើយវាចូលទៅក្នុងសីមាលោក អិលូវវាឆ្កួតវណាស់ទៅតាំងតែជេរលោកសង្ឃនោះផ្សេងៗ។

អែពួកញាតិក៏នាំគ្នាស្តីបន្ទោសចៅសន ហើយថាឆ្កួតមែនហើយ ធ្វើម្តេចនឹងរកគ្រូអែណានឹងមើលបាន។ អែចៅសនលឺពួកញាតិបន្ទោសដូច្នេះហើយ ក៏ខឹងណាស់ តាំងជេរដាសពាសទៅ ដល់ប្រកែកនឹងគេមិនឈ្នះ វាក៏យំផងព្រោះដោយសារក្មេង អែពួកញាតិក៏រិតតែជឿថា ចៅសនឆ្កួតមែន គឺពីដើមគ្រាន់តែថាលោកសង្ឃផឹកស្រា អិលូវវរខ្លាំងតាំងយំជេរគេអែងតែផ្តាស មិនស្គាល់ចាស់ក្មេងផង អែនាងម្តាយនោះក៏ភិតភ័យ ទើបរត់ទៅអែរោងពិធីតាថេន ដល់ហើយស្រែកហៅទៅថា «អោ ករុណាម្ចាស់សូមមេត្តាប្រោសសត្វ សូមទាននិមន្តចេញមកខាងក្រៅរោងសិន ត្បិតសត្វកើតវិបត្តិហើយ ព្រះគុណម្ចាស់»។ អែតាថេន លឺនាងសិកានិមន្តអោយចេញដូច្នេះ ក៏ស្ទុះម្នីម្នាជូតមាត់ជូតកស្អាត ហើយតាំងគ្រងចីវរជាបរិមណ្ឌលពាក់ ផ្គាំកាន់ឈើច្រត់ដើរលបៗចេញមកក្រៅហើយសួរ «កើតអីញោម បានជាភិតភ័យ រលះរលាំងយ៉ាងនេះ។ នាងសិកានោះ ក៏អង្គុយលុតជង្គង់ប្រណម្យដៃទូលថា «លោកម្ចាស់អិលូវនេះចៅសនកូនខ្ញុំករុណាវាចូលមកក្នុងសីមាលោកម្ចាស់ អិលូវកើតវរ ទៅជាឆ្កួតពុំដឹងអី ចេះតែស្រែកយំជេរគេអែងពាសទៅជេរត្រូវទាំងលោកម្ចាស់ផង»។ តាថេនឆ្លើយថា «ញោម អាចក្តី (អាចក្តី អ្នកដឹងសេចក្តីខុសត្រូវ ពាក្យបព្វជិតនិយាយជំនួសឈ្មោះខ្លួន និយាយទៅរកគ្រហស្ថ ដូចពាក្យអាត្មាដែរ អិលូវមិនឃើញមានប្រើពាក្យអាចក្តីនេះទេប្រើ អាត្មាវិញ) បានហាមហើយថា កុំអោយប្រហែស អោយហាមកូនហាមចៅកុំអោយវាចូលក្នុងសីមាពិធីនេះ ក្រែងវាកើតហេតុអិលូវមែនៗដូចពាក្យអាចក្តីថាចុះអិលូវនេះវានៅអែណាកូនញោមនោះ។ ករុណាម្ចាស់វានៅអែផ្ទះខ្ញុំករុណាអែនោះ។ អើបើដូច្នេះ ញោមទៅនាំខ្លួនវាមកអែរោងពិធីនេះអាចក្តីនឹងមើលរោគឆ្កួតនោះណ៎ាញោម នែញោម ពាក្យចាស់លោកថាបន្លាមុត គោងយកបន្លាដោះ ទឹកចូលត្រចៀកគោងយកទឹកចាក់ រោគឆ្កួតកើតមកពីរោងពិធី គោងមកមើលរក្សាអែរោងពិធីទើបសះស្បើយបាន។ អែនាងសិកានោះក៏សំពះលាតាថេនវិលទៅពឹងបងប្អូនប្រុសៗ ៣-៤នាក់អោយជួយថា

ប់យកខ្លួនចៅសនមកប្រគល់អោយតាថេន។ អែចៅសននោះត្រូវគេចាប់ដឹកនាំទៅដូច្នោះ ក៏រិតតែខឹងនឹងពួកញាតិ
តាំងបំរះននៀលជេរគេជេរអែង ហើយយំទៅតាមភាសាក្មេង តែធន់ពុំបាននឹងកំលាំងមនុស្សចាស់គេក៏នាំគ្នាចាប់សែ
ងពនាំទៅដល់រោងពិធីនោះ។ អែតាថេនក៏បបួលគ្នាទាំង៣នាក់ចេញមកក្រៅរោងហើយទទួលយកចៅសនចូលទៅ
ក្នុងរោងតាថេនក៏ប្រាប់ទៅថា ញោមទាំងអស់គ្នាសុទ្ធតែជាអ្នកមានគ្រោះនឹងនៅជិតរោងពិធីនេះពុំបាន ក្រែងខ្មោចព្រា
យអសនី នោះវាចូលរូប អាត្មានឹងស្រោចទឹកមន្តចៅសនហើយខ្មោចដែលនៅក្នុងរូបចៅសន វានឹងស្រែកជាខ្លាំងពុំ
ខាន បើដូច្នេះ ចូរញាតិញោមទាំងអស់គ្នាចៀសចេញទៅផ្ទះវិញអោយឆាប់ កុំនៅយូរក្រែង ខ្មោចវាចូល អែរូបចៅ
សននេះមិនអីទេ តែស្អែកខានស្អែកគង់នឹងជាមិនខាន។

អែពួកញាតិចៅសនលឺតាថេនថាដូច្នោះ ក៏នាំគ្នាសំពះលាលោកតាថេនវិលទៅផ្ទះទីទៃៗទៅ។ អែតាថេនចូលទៅក្នុង
រោងពិធី ហើយអោយគ្នាបីនាក់នោះចងចៅសនខ្ជាប់នឹងសសររោង តាំងកាន់រំពាត់ផ្តៅទាំង៤នាក់ ហើយកំហែងសួរ
ចៅសនថាអើ អាសនអាអែងថា ឃើញអញផឹកស្រាមែនរឺដូចេម្តច?ចៅសនឆ្លើយថា អើមែនខ្ញុំឃើញលោកតាអែង
ផឹកស្រា ស៊ីបាយល្ងាចប្រាកដទាំង៤នាក់។ ពួកទាំងនោះក៏កើត ទោសោហើយវាយចៅសន៤-៥រំពាត់ ចៅសនក៏ស្រែក
យំដោយសំលេងខ្លាំងៗ ទាំង៤នាក់ក៏សាកសួរទៀតថា ដូចម្តេចអាសនអែងថា ពួកយើងផឹកស្រាមែនរឺដូចម្តេច? ចៅ
សនថា អើអាអែងផឹកស្រាមែន អញឃើញច្បាស់នឹងភ្នែកអញហើយ។ អា៤នាក់ក៏រឹតតែវាយខ្លាំងលើសមុន។ ចៅស
នបាននូវសេចក្តីវេទនា ឈឺចាប់ពន់ពេកណាស់ ដល់ក្រោយទើបគិតថា អោអញនេះជាមនុស្សក្មេងម្នាក់អែង គេឆ្កួត
ពេញស្រុកទៅហើយតែអែងមិនធ្វើឆ្កួតតាមគេនោះ អាដែងពួកពាលនេះវានឹងវាយអញដល់សេចក្តីស្លាប់មិនខានឡើ
យ។ ល្ហើយចុះតោងធ្វើជាឆ្កួតតាមវាទៅចុះ ទើបរក្សាខ្លួនសុខបាន ចៅសនគិតដូច្នេះហើយ ទើបលើកដៃសំពះតាថេ
នហើយ សាសព្វប្រាប់ទៅថា ករុណាម្ចាស់ ខ្ញុំករុណានេះឆ្កួតពិតមែនហើយ សូមទានប្រោសអត់ទោស ខ្ញុំឆ្កួតមិនដឹងខ្លួន
មិនដឹងប្រាណទេព្រះគុណ បានជាថាព្រះគុណផឹកស្រា នោះគឺព្រះគុណពុំមែនឆាន់ស្រាទេ ខ្ញុំឆ្កួតមែនហើយ អិលូវខ្ញុំដឹងខ្លួ
នជាសះស្បើយហើយ រាងចាលហើយ ពីនេះទៅទៀត ខ្ញុំមិនថាព្រះគុណផឹកស្រាទេទាន។ តាថេនថា អើបើអែងលែង

ថាអញផឹកស្រា រាងចាលហើយអញក៏លែងវាយអែងតែត្រឹមនេះ។

ករុណាខ្ញុំព្រះករុណាលែងថាព្រះគុណឆាន់ស្រាហើយអំពីថ្ងៃនេះតទៅ ករុណាម្ចាស់។ អើបើមែនដូច្នេះអញក៏លែងវាយអែង បើអែងនៅតែថាអញៗ ក៏វាយអែងទាល់តែស្លាប់។ ថាហើយតាថេនក៏អោយស្រាយចំណងចៅសន ឃាត់ឃាំងចៅ សនមិនអោយចេញទៅក្រៅរោង។ អែចៅសនសោតទល់ចំណោះ ក៏នៅបំរើអា៤នាក់នោះទៅតាមអធ្យាស្រ័យ លុះថ្ងៃគំរប់៧ ជាពេលយប់ស្ងាត់ចៅសនក៏ដេកលក់ទៅ។ អែចៅពាល៤នាក់នោះតាំងរើគ្រឿងកំណល់ពិធីយកប្រាក់ យកសំពត់ ផ្តិល ជើងពាន វេចសំពាយហើយ ក៏នាំគ្នាលបរត់ចេញចាកស្រុកនោះទៅកាន់ស្រុកដទៃទៅ។ លុះវេលាព្រឹកចៅសនភ្ញាក់ឡើង ស្រាប់តែស្ងាត់ឈឹងទាំងរោង មើលទៅគ្រឿងតាំងពិធីនោះ ក៏បាត់អស់រលីងគ្មានសល់ដល់តិចឡើយ ចៅសនក៏ដឹងថាតាថេនលួចរបស់ទ្រព្យរត់ទៅអស់ហើយ ទើបចៅសនដើរចេញចាករោងចូលទៅផ្ទះអាត្មា។ អែបណ្តាញាតិមិត្តឃើញចៅសនដើរមកដូច្នោះហើយ  សួរថា  ដូចម្តេចទៅ ជីសនអើយរោគនោះបានស្រាកស្រានធូរខ្លួនប្រាណខ្លះហើយរឺដូចម្តេចទៅ។ ចៅសនក៏តបថា នៅឡើយតែថា អិលូវនេះអំពើចំកួតនោះ វានៅលើអ្នកស្រុកទាំងអស់គ្នា អើអែងជាៗសោះ គេឆ្កួតពេញទាំងស្រុក ក៏ត្រលប់ថាអែងឆ្កួតវិញ អើមីងមា យាយតាទាំងអស់គ្នាទៅជឿអាមនុស្សពាលនោះទុកជាគ្រូ ថាលោកធុតង្គរុក្ខមូលវិសេសណាស់ អិលូវគ្រឿងប្រដាប់ដែលតាំងពិធីពលីការនោះ លោកធុតង្គទោះបន្លុង ឆាកយកទៅអស់ហើយអោយអញ្ជើញទៅមើលចុះ។ ថាហើយចៅសនក៏ដើរត្រង់ទៅផ្ទះ

អែបណ្តាអ្នកស្រុកបានលឺចៅសនថាដូច្នេះហើយ ខ្លះក៏សង្ស័យថា ក្រែងពិតដូចពាក្យចៅសនថារឺ ទើបនាំគ្នាទៅអែរោងពិធី ស្រាប់តែឃើញស្ងាត់ឈឹងសូន្យ ក៏ចូលទៅក្នុងរោង យល់របស់ទ្រព្យខ្លួននោះវិនាសអស់ទៅ ដោយដៃមនុស្សពាលទាំង ៤នាក់នោះអែង ហើយទើបនាំគ្នាមកផ្ទះទីទៃៗកើតសេចក្តីវិប្បដិសារីលើកទោស អាត្មា ឃើញថាជាមនុស្សអិតបញ្ញា ទៅជឿពាលអោយវាបញ្ឆោតបាន គឺខ្លួនឆ្កួតប្រាកដ ចៅសនគ្មាជាសោះក៏នាំគ្នាជឿថាឆ្កួតវិញ។

ចប់និទានតាថេនតែប៉ុណ្ណោះ